ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 31-Aug-2016, 11:13
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៦**

**ម៉ោង ០៩:០៣នាទី**

**សវនាការលើកទី៤២៥**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ន
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី

ចៅក្រម ម៉ាទីន ខារ៉ុបគីន
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ជា ស៊ីវហ័ង

កញ្ញា អេវេលីន ខាំផូស សង់ចេស

*(Ms. Evelyn CAMPOS SANCHEZ)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន
*(Mr. Nicolas KOUMJIAN)*

លោក សេង លាង

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

លោក វីល្លៀម ស្មីត *(Mr. William Smith)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វិចទ័រ កូប៉េ*(Mr.Victor KOPPE)*

លោក លីវ សុវណ្ណា

កញ្ញា ដូរីន ជិន (Ms. Doreen CHEN)

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោក ឡោ ជុនធី

លោក វ៉ែន ពៅ

លោកស្រី ទី ស្រ៊ីនណា

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្វ សុទ្ធារី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ខេល លីសាក់ | អង់គ្លេស |
| លោក នីកូឡាស គូមជែន | អង់គ្លេស |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក កាំង ហ្គេកអ៊ាវ ហៅ ឌុច (2-TCW-916) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅ សាក្សី៖ លោក គាំង ហ្គេកអ៊ាវ ហៅ ឌុច** (2-TCW-916)

សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី ...................................................................... ទំព័រ ៤

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៣:៤៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី កាំង ហ្គេកអ៊ាវ បញ្ចប់ ហើយនិងបន្ទាប់មក អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សារណាផ្ទាល់មាត់របស់ភាគីលើសំណើសុំរបស់មេធាវីការពារក្តីលោក ខៀវ សំផន ឯកសារ E420 ហើយនិងស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-236។ ហើយមុននឹងដំណើរការសវនាការ គឺអង្គជំនុំជម្រះសូមជូនដំណឹងដល់ភាគីនៃរឿងក្តីទាំងអស់ថា នៅក្នុងកិច្ចដំណើរការសវនាការនៅថ្ងៃនេះ ហើយនិងថ្ងៃបន្តបន្ទាប់ទៀត ដោយចៅក្រម យ៉ា សាខន ដែលជាចៅក្រមជាតិលោកអវត្តមានដោយមូលហេតុគាត់មានបញ្ហាសុខភាពមិនអាចចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះបាន។ ហើយដូចគ្នានេះដែរ គឺលោកចៅក្រម ក្លូឌា ហ្វេនស៍ ដែលជាចៅក្រមអន្តរជាតិអវត្តមានដោយមូលហេតុគាត់មានធុរៈចំបាច់ផ្ទាល់ខ្លួន មិនអាចចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះបាន។ បន្ទាប់ពីយើងខ្ញុំពិគ្រោះ ពិភាក្សាយោបល់ជាមួយនឹងចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងយើងសម្រេចតែងតាំងលោកចៅក្រម ធូ មណី ដែលជាចៅក្រមបម្រុងខាងភាគីជាតិជំនួសកន្លែងចៅក្រម យ៉ា សាខន ដែលអវត្តមាន ហើយរហូតតែដល់ពេលណាដែល ចៅក្រម យ៉ា សាខន មានវត្តមាន និងមានលទ្ធភាពអាចចូលរួមបំពេញការងារនៅក្នុងកិច្ចដំណើរការសវនាការរបស់អង្គជំនុំជម្រះសាលាដំបូងវិញបាន។

ហើយដូចគ្នានេះដែរ ហើយចៅក្រម ម៉ាទីន ខារ៉ុបគីន ដែលជាចៅក្រមបម្រុងអន្តរជាតិជំនួសកន្លែងចៅក្រម ក្លូឌា ហ្វេនស៍ ដែលអវត្តមានរហូតដល់ពេលណាដែលចៅក្រម ក្លូឌា ហ្វេនស៍ មានវត្តមាន និងមានលទ្ធភាពអាចបំពេញការងារនៅក្នុងការចូលរួមកិច្ចដំណើរការសវនាការរបស់សាលាដំបូងយើងវិញបាន។ ហើយការអនុវត្តនេះដោយយោងតាមបទប្បញ្ញត្តិនៃវិធាន៧៩(៤) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

កញ្ញា ជា ស៊ីវហ៉ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមាន និងបុគ្គលដែលអង្គជំនុំ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

[០៩:០៦:១២]

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះ មានវត្តមាន ដោយឡែក លោក នួន ជា មានវត្តនៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមាននៅក្នុងបន្ទប់សវនាការដោយផ្ទាល់នៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីដែលត្រូវមកផ្ដល់សក្ខីកម្មបញ្ចប់នៅព្រឹកនេះ គឺលោក កាំង ហ្កេកអ៊ាវ ហៅ ឌុច។ លោកមានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការ។ ដើមបណ្ដឹងរដ្ឋប្បវេណីដែលត្រូវមកផ្ដល់សក្ខីកម្មបន្ទាប់ទៀតមានរហស្សនាម 2-TCCP-236។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណកញ្ញា ជា ស៊ីវហ័ង។

ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា គាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ដង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៦។ មេធាវីការពារក្ដីរបស់ខ្លួនបានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា មិនអាចបកស្រាយថា ជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្ដីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះគ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

[០៩:០៧:៤០]

បានឃើញកំណត់ហេតុពិនិត្យសុខភាព ជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យ ព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៦ បានកត់

សម្គាល់ ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះថា មានអាការៈឈឺចង្កេះជាប្រចាំ និងអាចឈឺកាន់តែខ្លាំង បើអង្គុយយូរ និងបានផ្តល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការពីបន្ទប់មួយស្ថិតនៅក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥)នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

[០៩:០៨:៥១]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រី ចៅក្រម សូមជម្រាបសួរភាគីទាំង និងលោកសាក្សី។

ខ្ញុំនឹងបន្តចាប់ផ្តើមពីចំណុចដែលខ្ញុំផ្អាកពីថ្ងៃព្រហស្បតិ៍ ខ្ញុំ<បាន>អានឲ្យលោកសាក្សីស្តាប់អំពីសក្ខីកម្មរបស់លោកពីមុន ហើយនិងសួរសំណួរលោកពីបញ្ហានោះ។ ខ្ញុំបានបញ្ឈប់ត្រង់សេចក្តីដកស្រង់លេខ១៣។ អ្វីដែលខ្ញុំត្រូវបន្តហ្នឹង ខ្ញុំនឹងជូនឯកសារជាក្រដាសដោយមានការ -- ដោយសូមការអនុញ្ញាតពីលោកប្រធាន ដោយចាប់ផ្តើមបន្តពីលេខ១៣ ហើយខ្ញុំនឹងសួរសំណួរបន្តបន្ទាប់។

ខ្ញុំសូមបន្ថែមលោកប្រធានឯកសារដែលខ្ញុំត្រូវសួរសំណួរ គឺឯកសារ E3/2133, ខ្មែរ ERN 00006728, អង់គ្លេស 00242285, បារាំង 0025091*(ស៊ីក)*។ ខ្ញុំសូមអនុញ្ញាត ដើម្បីជូនឯកសារនេះទៅលោកសាក្សីលោក<>ប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[០៩:១០:៣៦]

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ដូចដែលខ្ញុំបានប្រាប់លោកខាងដើម គឺថា កាលពីថ្ងៃព្រហស្បតិ៍ ខ្ញុំបានអានសេចក្ដីដកស្រង់ចេញពីភស្តុតាងរបស់លោកគឺ E3/1578, ទំព័រអង់គ្លេស 00194552, ខ្មែរ <00178027>, បារាំង <00178040>។ នៅក្នុងសេចក្ដីដកស្រង់នេះ យើងនិយាយអំពីឯកសារ E3/2133 ហើយនៅក្នុងសក្ខីកម្មរបស់លោក លោកនិយាយថា "ឯកសារនេះបង្ហាញច្បាស់ថា គឺមនុស្ស១៧នាក់ បញ្ជូនពីព្រៃសទៅជើងឯកនៅពេលនោះ។ ដូច្នេះ គឺថា អង្គហេតុនេះ គឺមានបញ្ជាក់ច្បាស់។ ខ្ញុំផ្ទាល់ មិនបានដឹងពីរឿងនេះទេ ឯកសារនេះ គឺថាមានកុមារ ១៦០នាក់ត្រូវបានបញ្ជូនថ្ងៃនោះដែរ ទៅជើងឯក។ ទាក់ទងនឹងឯកសារនេះ តើត្រូវដែរឬទេនៅពេលនោះ លោកមិនបានដឹងផ្ទាល់ខ្លួនអំពីហេតុការណ៍នេះទេ?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ឯកសារនេះ ការឆ្លើយរបស់ខ្ញុំនៅពេលសវនាការ -- សុំទោស នៅពេលសម័យស៊ើបអង្កេត វាច្បាស់លាស់ណាស់ហើយ។ បានន័យថា ខ្ញុំមិនបដិសេធសភាពការណ៍នេះទេ ទទួលស្គាល់។ តែឯកសារនេះ -- តែដំណើរការថ្ងៃនោះ ខ្ញុំមិនបានដឹងទេ ឬក៏ថាខ្ញុំមិនចងចាំ ប៉ុន្តែនិយាយឲ្យត្រង់គឺខ្ញុំមិនបានដឹងទេ។ ជាគោលការណ៍ដែលគេមានហើយគេអនុវត្តតាមភារកិច្ចរបស់គេ គឺមិត្តហ៊ិ ហើយនិង មិត្តហ៊ុយ។

[០៩:១៣:១៦]

**ស៖** លោកសាក្សី ខ្ញុំនឹងសួរបន្តពីបញ្ហានេះ ហើយនិងសួរពី ERN ដែលពាក់ព័ន្ធទៅនឹងអ្វីដែលត្រូវកើតឡើងចំពោះកុមាររបស់កម្មាភិបាលដែលត្រូវបានគេចាប់ខ្លួនយកមកឃុំនៅស-២១។

លោកប្រធាន ខ្ញុំសូមអនុញ្ញាត បង្ហាញសាក្សីនូវសក្ខីកម្មរបស់កម្មាភិបាលនារីម្នាក់ បាទ មកពីជាអតីតយុទ្ធនារី ដែលនៅក្នុង E3/7633។ ខ្មែរជាអត្ថបទ គឺ 00052430 ហើយអង់គ្លេស 00863759 បារាំងនឹងជូនតាមក្រោយ។ ខ្ញុំសូមអនុញ្ញាតដើម្បីបង្ហាញឯកសារនេះ ហើយនិងសម្រង់ជូនសាក្សី ដើម្បីគាត់អាចអានបានលោកប្រធាន បាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី កម្មាភិបាលនារីម្នាក់នេះ គាត់បានឆ្លើយទៅមជ្ឈមណ្ឌលឯកសារកម្ពុជា គឺដូចខាងក្រោមនេះ ខ្ញុំដកស្រង់៖ “សំណួរ៖ នៅពេលដែលលោក<ស្រី>ធ្វើការនៅស្ទឹងបាគូ តើការងារសំខាន់របស់លោកស្រីធ្វើអ្វី? ឆ្លើយ៖ ការងារប្រចាំថ្ងៃ គឺស្ទូងស្រូវ ជីកប្រឡាយ ហើយនិងលើកទំនប់។ ក្រៅពីការដកស្ទូង ខ្ញុំមើលការខុសត្រូវលើកុមារ<៧០ ទៅ>៨០នាក់ ដែល<គេបានបំបែកចេញពីឪពុកម្តាយរបស់ពួកគេតាំងពីឆ្នាំ៧៥>។ <សំណួរនៅខាងក្រោមបន្តិចហ្នឹងសួរថា៖> តើ<អ្នកស្រីធ្វើយ៉ាងម៉េចក្នុង>ការមើលកុមារម្នាក់ឯង ពី៧០ ទៅ៨០នាក់ ម្នាក់ឯងហ្នឹង ធ្វើអ្វីខ្លះ? ឆ្លើយ៖ <គេប្រាប់>ខ្ញុំ<ឲ្យណែនាំក្មេងៗទាំងនោះឲ្យ>ធ្វើការងារ<ដូចជាច្រូតស្រូវជាដើម”។ បន្ទាប់មកនៅទំព័រខ្មែរ 0005 2433 អង់គ្លេស 00863761 គាត់និយាយអំពី-->

**អ្នកបកប្រែ៖**

លោកប្រធាន សូមអនុញ្ញាត គាត់ទៅលឿនពេកទំព័រ ហើយនិង ERN អ្នកបកប្រែតាមមិនទាន់បាទ។

[០៩:១៦:០៩]

**ប្រធានអង្គជំនុំ៖**

លោកៗ លោកមេធាវី វ៉ិចទ័រ កូប៉េ បញ្ជាក់លេខ ERN សាជាថ្មីម្តងទៀត ឯកសារអំមិញនេះអ្នកបកប្រែភាសាអត់ទាន់ទេ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** បាទ នៅក្នុងឯកសារដដែល គឺខ្មែរ ERN 00052433, អង់គ្លេស 00863761។ គាត់និយាយអំពី ហ៊ុយ ជាប្រធាន ទីកន្លែងដែលកម្មាភិបាលនារីនេះធ្វើការ ហើយនៅខាងក្រោមនោះបន្តិចនៅទំព័រខ្មែរ នៅត្រង់ <000052434> *(ស៊ីក),* អង់គ្លេស 0086373។ គាត់និយាយថា “កុមារៗ ត្រូវបានយកចេញពីឪពុកម្តាយដែលគេចោទថា មានទំនាក់ទំនងនិន្នាការនយោបាយជាមួយអ្នកនៅភ្នំពេញ” ។ “តើគេយកកុមារចេញពីអ្នកឯង ពេលណា?” ហើយគាត់ឆ្លើយថា៖ ប្រហែលជា<កន្លះខែមុន>ការដួលរលំ<របស់អាពត>។” <ហើយបន្ទាប់មកគាត់និយាយអំពីកុមារៗប្រហែល៣០ ឬ៤០នាក់។> អ៊ីចឹង គឺថាពិនិត្យមើលភស្តុតាងដែលខ្ញុំអានជូនលោកស្តាប់នេះ គឺថាគាត់បាននិយាយអំពីថា គាត់បានមើលកុមាររបស់កម្មាភិបាលដែលត្រូវគេបានចាប់ខ្លួននៅព្រៃស។ តើនេះជាអ្វីដែលលោកបានដឹង នៅ

ពេលសម័យនោះដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

អញ្ជើញលោកសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

បាទ លោកប្រធាន ខ្ញុំសូមជំទាស់ ពីព្រោះមេធាវីការពារក្តី នាំមុខសាក្សី។ <ខ្ញុំគិតថា គាត់ត្រូវសួរសំណួរបើកសិន ថាតើ>ស្ទឹងបាគូ<ជាអ្វី កន្លែងដែលស្ត្រីនោះ>គាត់ធ្វើការ។ <ហើយបន្ទាប់មកទើបបង្ហាញភស្តុតាងថា តើវាពិតឬទេថាស្ទឹងបាគូហ្នឹងជាផ្នែកមួយរបស់ព្រៃស មុនពេលគាត់អះអាងបែបនោះទៅ>សាក្សី<>។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំបន្ថែមសំណួរនេះទៅសំណួរពីមុនរបស់ខ្ញុំ។ លោកសាក្សី កម្មាភិបាលនារីនេះ គាត់បាននិយាយអំពីស្ទឹងបាគូ ហើយគាត់និយាយយោងដល់ ហ៊ុយ។ តើស្ទឹងបាគូហ្នឹងជាកន្លែងអ្វី? ស្ថិតនៅជាផ្នែករបស់កន្លែងណាដែរ?

[០៩:១៨:៤៩]

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន មេធាវីមុនដំបូង ឲ្យលេខទំព័រ ERN របស់ខ្ញុំ 430 នៅខាងចុង ប៉ុន្តែដល់អាន បានតែពីរបីម៉ាត់នៅខាងដើម ស្រាប់វង្វេងទៅឯណា។ ខ្ញុំមើល ខ្ញុំតាមអត់ទាន់ទេៗ ហ្នឹងជម្រាបដោយត្រង់។ រួចដល់ក្រោយមក លោកមេធាវីឲ្យលេខ ERN ទៅអ្នកបកប្រែ 433 នៅខាងចុង។ ខ្ញុំមកមើល 433 នៅខាងចុង ទៅឯណាទៀត ផ្សេងទៅទៀត។ ដូច្នេះ ខ្ញុំស្នើឲ្យបានយើងអានទាំងអស់គ្នា ទាន់ តាមទាន់ឯកសារដែលលោកមេធាវីដាក់។ បើមិនអ៊ីចឹងទេ វង្វេង មិនដឹងជារឿងស្អីជាស្អីទេ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីរៀបចំសំណួរចុងក្រោយរបស់លោកសាឡើងវិញ ដែលផ្អែកលើមូលដ្ឋាននៃឯកសារភស្តុតាងដែលយោងនៅក្នុងការតាំងសំណួរ ដើម្បីរៀបរយឲ្យបានត្រឹមត្រូវ ដើម្បីសាក្សីស្តាប់បាន ហើយនិងដើម្បីរួមវិភាគទានក្នុងការស្វែងរកការពិតនូវរឿងក្តីនេះ។ ខំ បើសាក្សីឆ្លើយស្មាន ឬក៏មិនអាច

ស្តាប់ ឆ្លើយតបបានទេ ប្រសិនបើលោកមានភាពមិនច្បាស់លាស់ ក្នុងការរៀបចំនូវសំណួរ និងឯកសារ យោងឲ្យបានច្បាស់លាស់។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី ខ្ញុំបានគូសបញ្ជាក់ពីផ្នែកពាក់ព័ន្ធឲ្យលោកបានពិនិត្យមើល ដើម្បីឲ្យលោកតាមទាន់ គឺទៅត្រង់កន្លែងគូសពណ៌លឿង។ ប៉ុន្តែខ្ញុំសង្ខេបខ្លឹមសារនោះ គឺថាដំបូង ខ្ញុំនឹងសួរសំណួរ តើអ្វីស្ទឹងបាគូហ្នឹង ជាកន្លែងអ្វី នៅពេលនោះ?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន សំណួររបស់មេធាវីលោតទៅនេះ លោតទៅនោះ ខ្ញុំពិបាកតាម។ ដូច្នេះ ឥឡូវលោកឯកសារហ្នឹង ហើយលោកអានទំព័រណា? ឬក៏មិនយកឯកសារនេះទេលោកសួរខ្ញុំ ថាបាគូនុ៎ងស្អី? អាហ្នឹង ខ្ញុំជម្រាបបាន។ អាហ្នឹង និយាយគ្នាឲ្យច្បាស់ណ៎ា។ យកឯកសារនេះ ឬក៏អានឲ្យសព្វគ្រប់ ឲ្យបានយើងដឹងទាំងអស់គ្នា ហើយសឹមលោកសួរ ឬមួយលោកលោកមិនបាច់គិតឯកសារ សួរថាបាគូជាស្អី? អាហ្នឹង ខ្ញុំជម្រាបបាន។

[០៩:២១:២១]

**ប្រធានអង្គជំនុំ៖**

លោក។ ឥឡូវ ឌុច លោកសាក្សីឆ្លើយសិន តើលោកស្គាល់បាគូទេ? ហើយបាគូជាទីកន្លែងណា? ហើយមានការពាក់ព័ន្ធយ៉ាងម៉េចដែរ ជាមួយនឹងមន្ទីរសន្តិសុខស-២១?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ បាគូ ពីដើមយើងខ្ញុំទៅតាំងនៅ មុនខែ១០ ១៩៧៥ ដល់ក្រោយមកខាង៧០៣ បងពីន គាត់យកវិញ ខ្ញុំប្រគល់ជូនគាត់វិញ។ ដល់ក្រោយមកអង្គភាពនេះទៅសមរភូមិអស់ទៅ គេប្រគល់បាគូមកឲ្យខ្ញុំវិញ។ ដូច្នេះ បាគូនេះមិនមែននៅក្នុងដែនស-២១ រហូតចប់ចុងចប់ដើមទេ ប្រហែលជានៅចុងឆ្នាំ១៩៧៧ បានៗមកដល់ស-២១វិញ។ បាគូហ្នឹងមានមនុស្សតិចណាស់។ ឯចំណែកទីតាំងរបស់ មិត្តហ៊ុយ ដូចនៅឆ្ងាយពីបាគូ កន្លែងនុ៎ងខ្ញុំអត់ស្គាល់ទេ។ នេះ គឺច្បាស់លាស់អ៊ីចឹង អានេះពីបញ្ហាបាគូ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សាក្សីរូបនោះ គាត់បាននិយាយអំពីប្រធានឈ្មោះ ហ៊ុយ ហើយគាត់ក៏បាននិយាយពីការ

មើលកុមារ ដែលឪពុកម្ដាយរបស់គេនោះ ត្រូវបានគេចោទថាមានជាប់និន្នាការ<នយោបាយ>។ សំណួរខ្ញុំ ខ្ញុំសួរភ្ជាប់ពីសំណួរពីមុនទៅលោកសាក្សី ថាតើលោកដឹង ឬទេថា មានកន្លែងផ្សេងទៀត អាចជាព្រៃស ឬក៏កន្លែងផ្សេងដែលមាននារី ដែលគេមើលកុមារ ហើយដែលម្ដាយឪពុករបស់គេត្រូវបានគេចាប់បញ្ជូនមកស-២១នោះ?

[០៩:២៣:២០]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយ!

អញ្ជើញៗលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកមេធាវី កូប៉េ ខ្ញុំគិតថាលោកគួរតែធ្វើការបែងចែកឲ្យបានច្បាស់។ លោកនិយាយអំពីកូននៃកម្មាភិបាលដែលត្រូវបញ្ជូនទៅស-២១ វាអាចមានកូនរបស់<អ្នក>ដែលត្រូវបញ្ជូនទៅអប់រំកែប្រែ។ អ៊ីចឹង កុមារទាំងពីរប្រភេទនេះ មិនមានជោគវាសនាដូចគ្នាទេ។ យើងបានស្ដាប់ចម្លើយសាក្សីជាច្រើនរួចមកហើយថា នៅពេលអ្នកណាម្នាក់ដែលត្រូវបានឃុំនៅស-២១ ត្រូវបានសម្លាប់ចោលហ្នឹង ក្រុមគ្រួសារក៏គេសម្លាប់ដែរ។ អ៊ីចឹងវាមិនដូចករណីដែល អ្នកដែលត្រូវបានបញ្ជូនទៅអប់រំកែប្រែទេ។ អ៊ីចឹងលោកគួរតែបែងចែកឲ្យបានច្បាស់ត្រង់ចំណុចនេះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំសូមនិយាយឲ្យជាក់លាក់ ដោយយោងទៅរកសក្ខីកម្មរបស់បុគ្គលម្នាក់នេះ។ នាងបាននិយាយថាគាត់បានមើលកុមារៗ សូមដកស្រង់៖ "ដែលកុមារនោះ គេយកមកពីឪពុកម្ដាយដែល គេចោទប្រកាន់ថា មានជាប់ទាក់ទងនិន្នាការនយោបាយមកពីភ្នំពេញ"។ ចប់សេចក្ដីដកស្រង់។ តើលោកសាក្សីអាចមានប្រតិកម្មអ្វីតបទៅនឹងសម្ដីរបស់គាត់នេះដែរឬទេ? បាទ សេចក្ដីដកស្រង់ជាក់លាក់ហ្នឹង ខ្មែរ 00052434 បាទ។

[០៩:២៥:០៨]

**លោក កាំង ហ្គេកអាវ៖**

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ក្នុងឯកសារនេះមានន័យមិនដូចគ្នាពីរ ច្របូកច្របល់។ នៅទំព័រ៣៣០ -- អូ៎! សុំទោស ៤៣០ ខ្ញុំអានតែចុងទេ លេខចុងបីខ្ទង់៖ "គេដកយើងឲ្យទៅ

01324186



មើលកុមារជម្លៀសពី៧៥។ គេជម្លៀសទៅ គេដកម្តាយនៅដោយខ្លួន ហើយកូនៗប្រមូលយកមកទុកហ្នឹង។ គេប្រគល់កុមារ៧០, ៨០នាក់ ឲ្យយើង។" ដូច្នេះក្នុងន័យនេះ ក្នុងន័យទំព័រ៤៣០ គឺជនជម្លៀស។ សូមបញ្ជាក់ថា គ្មានជនជម្លៀសឯណាទៅចូលនៅព្រៃសរបស់យើងខ្ញុំទេ សុទ្ធតែពួកយុទ្ធជន យុទ្ធនារីដែលមានពិរុទ្ធ។ ហើយដល់ក្រោយមក កូនកម្មាភិបាលយកទៅដាក់នៅនុ៎ង។ ដូច្នេះបញ្ជាក់ សក្ខីកម្មនេះមិនច្បាស់ មិន -- ខុសតែម្តង។ គ្មានអ្នកជម្លៀសឯណាចូលទៅព្រៃសទេ។ ហ្នឹងនិយាយគ្នាឲ្យច្បាស់។ ដំបូងមានយុទ្ធជន យុទ្ធនារី ដល់ក្រោយមកមានកម្មាភិបាលដែលមានកូនមានអីទៅជាមួយ។

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ៗ! ឌុច កុំអាលទាន់។ មានបញ្ហា ក្បាលមីក្រូហ្វូនមិនទាន់ប្រតិបត្តិការ អំមិញវាច្រឡំលោតនេះទៅ គេបិទទៅ។

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ ហើយដល់ទំព័រ៤៣៤ ឈ្មោះ ប៉ាន់ អ្នកឲ្យសក្ខីភាពនោះឈ្មោះ ប៉ាន់៖ "កុមារហ្នឹង គេជម្លៀសដូចថា ម៉ែឪជាប់និន្នាការអ្វីៗនៅក្នុងភ្នំពេញហ្នឹងណ៎ា។ គេដកម្តាយទៅ កុមារហ្នឹងគេដកមកឯណេះ។" ដូច្នេះសក្ខីកម្មត្រង់នេះ មិនច្បាស់ទេ មានន័យពាំត្រណោត។ "ឬមួយពួកនេះ ជាពួកជនជម្លៀស ឬមួយជាកម្មាភិបាលបដិវត្តន៍"។ ដូច្នេះ សក្ខីម្មនេះមិនច្បាស់លាស់។ ខ្ញុំសូមនិយាយថា សក្ខីកម្មនេះ មិនច្បាស់លាស់។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមលោកទុកចម្លើយនោះមួយឡែកសិន។ តើលោកដឹងថា មានទីកន្លែងណានៅព្រៃសដែលគេចាត់តាំងនារីឲ្យមើលកុមារៗ ដែលឪពុកម្តាយរបស់គេត្រូវបានចាប់ខ្លួនដោយមូលហេតុអ្វីក៏ដោយ។ តើធ្លាប់ដឹងពីរឿងហ្នឹងទេ?

**ឆ៖** ខ្ញុំមិនដឹងទេៗ។

[០៩:២៨:១៧]

**ស៖** អរគុណលោកសាក្សី ខ្ញុំនឹងបន្តទៅបញ្ហាមួយទៀត។ ពាក់ព័ន្ធនឹងបញ្ហានេះដែរ ខ្ញុំដឹងថាខ្ញុំនឹងសួរសំណួរនេះ គឺថា <លោក>មិនបានឃើញបញ្ជីអ្នកទោសថ្មីរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតទេ។ ហើយប៉ុន្តែទោះយ៉ាងហ្នឹងក៏ដោយ ខ្ញុំត្រូវសួរលោក។ បញ្ជីថ្មីនេះនិយាយអំពី គឺថាមានអ្នកទោស ១៥.១០១នាក់ <នៅស-២១> បាទ អ៊ីចឹងគឺថានៅក្នុងបញ្ជីនេះ យើងបានកំណត់អត្តសញ្ញាណគឺ

ថា មាន៦៩៩ <នាក់> នោះត្រូវបានចុះបញ្ជីជាប្រពន្ធរបស់កម្មាភិបាល។ បាទ ប្រហែលជា ៤,៦៣ ភាគរយនៃចំនួនសរុប។ <> ក្រៅពី ៦៩៩ នេះគឺថា មាន២០២នាក់ គឺត្រូវបានគេចុះបញ្ជីថាជាប្រពន្ធ បាទ ជាប្រពន្ធ មិនបានដាក់ថាប្រពន្ធរបស់អ្នកណាទេ គឺថា ប្រហែលជា១,៣៤ភាគរយនៃចំនួនសរុប។ បាទ អ៊ីចឹង<សំណួរខ្ញុំ>គឺថា <រវាងមួយកន្លះ និង> ប្រាំភាគរយនៃអ្នកទោសដែលត្រូវគេចាប់ខ្លួន <គឺដោយសារ>ជាប្រពន្ធរបស់ ឧបមាថា អ្នកដែលមានប្ដីហ្នឹង គឺថា តើតួលេខជាភាគរយហ្នឹងវាផ្ទុះបញ្ចាំងពីអ្វីដែលលោកចងចាំដែរឬទេ លោកសាក្សី?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថាមេធាវីការពារក្ដីគឺ សួរនាំមុខសាក្សីដោយសេចក្ដីស្រង់ព័ត៌មានរបស់ខ្លួន ដែលខ្លួនយកមកពីបញ្ជីនោះ។ <ខ្ញុំមិនជំទាស់ទេបើមេធាវីចង់>ឲ្យ<>សាក្សី<>ផ្ដល់សេចក្ដីសង្កេត<> ប៉ុន្តែ<ខ្ញុំគិតថា គាត់កំពុងតែ>ផ្ដល់សេចក្ដីសន្និដ្ឋាន<ទៅឲ្យសាក្សី ជាជាងសួរឲ្យផ្ដល់ការសង្កេត>។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** បើសិនជាខ្ញុំធ្វើ<តាមបែបម្យ៉ាងទៀតនោះ នឹងមានការ>ជំទាស់<ថា ខ្ញុំត្រូវតែផ្ដល់ប្រភពព័ត៌មានជាមុនសិន។ ដូច្នេះទោះបីជាខ្ញុំសួរតាមរបៀបណាក៏ដោយ ក៏ខ្ញុំត្រូវបានគេជំទាស់ដែរ។> ប៉ុន្តែខ្ញុំសូមសួរជាទូទៅទៅវិញបាទ។<> តើស្ត្រីដែលត្រូវបានចាប់ខ្លួន<ដោយសារតែជាប្រពន្ធរបស់គេ>នោះមានភាគរយប៉ុន្មាន? <តើស្ត្រីដែលត្រូវបានចាប់ខ្លួនដោយសារតែជាប្រពន្ធ>មានប៉ុន្មានភាគរយ <បើធៀបជាមួយនឹងអ្នកទោសសរុប>?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន តាំងពីថ្ងៃ៣១ កក្កដា ២០០៧ ដែលខ្ញុំចូលមកដល់ អ.វ.ត.ក នេះ រហូតដល់ថ្ងៃ១០ មីនា -- មេសា ២០១២ ខ្ញុំអត់ទាន់ឃើញបញ្ជី ១៥.០០០ ប្លាយនាក់ទេ ដែលយើងប្រើរហូតហូរហែមក គឺបញ្ជី មួយម៉ឺនពីរពាន់ប៉ុន្មានរយ ដែលយើងបានឆ្លាក់នៅផ្ទាំងសិលានៅទួលស្លែង។ ដូច្នេះ លោកយកបញ្ជីនេះមក ហើយអត់ទាំងបញ្ជីនោះ ឲ្យខ្ញុំធ្វើស្ថិតិប៉ុន្មានភាគរយៗយ៉ាងម៉េច សូម្បីតែបញ្ជី ១២.០០០ នោះក៏ខ្ញុំមិនដែលបានធ្វើស្ថិតិទេ។ រួចឥឡូវយកមកសួរស្ថិតិនេះ ខ្ញុំជា

គ្រូគណិតវិទ្យាមែន តែខ្ញុំធ្វើមិនទាន់ទេ បើអត់តួលេខជាមូលដ្ឋាន។

[០៩:៣២:៣៥]

**ស៖** ខ្ញុំមិនសួរ សូមឲ្យលោកយល់ស្របទៅលើភាគរយជាក់ស្តែងណាមួយទេ។ ប៉ុន្តែយើងនិយាយពីចំនួនភាគច្រើន គឺប្រាំភាគរយនៃអ្នកទោសហ្នឹងត្រូវបានចាប់ខ្លួន ដោយសារតែខ្លួនមានប្តី ឬក៏ប្តីជាប់និន្នាការអីហ្នឹង <ហើយអ្នកទោស៩៥ភាគរយទៀតមិនត្រូវបានចាប់ខ្លួនដោយសារតែជាប់ពាក់ព័ន្ធនឹងគ្រួសារទេ។> ថាតើជាចំនួនហ្នឹងប៉ាន់ប្រមាណហ្នឹងអាចត្រឹមត្រូវទេថា មានប្រាំភាគរយ?

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ។

**លោក ឌេល លីសាក់៖**

បាទ ជាថ្មីម្តងទៀតហើយ គឺមេធាវីការពារក្តី<កំពុងតែផ្តល់ការសន្និដ្ឋានទៅឲ្យសាក្សី នូវព័ត៌មានពីចំនួនមនុស្ស ដែលគេ>កំណត់ថាជាប្រពន្ធរបស់អ្នកទោស។ ប៉ុន្តែចំនួនទាំងនោះមិនបានប្រាប់ថាការចាប់ខ្លួនដោយសារជាសាច់ញាតិ ឬក៏យ៉ាងណាណីទេ។ <ដូច្នេះខ្ញុំគិតថា>មេធាវីការពារក្តី<មិនមានមូលដ្ឋានក្នុងការ>លើកតួលេខជាភាគរយបែបនេះ<ទៅឲ្យសាក្សី ថាជាចំនួនមនុស្សដែលត្រូវបានចាប់ខ្លួនដោយសារតែពួកគេជាសាច់ញាតិ ឬជាប្រពន្ធនោះទេ។> គាត់អាចសួរបាន គ្រាន់តែសួរអំពីអត្តសញ្ញាណអ្នកដែលគេចាប់មកដោយប្រើពាក្យថាប្រពន្ធអីជាដើមនេះ។

**លោក វិុចទ័រ កូប៉េះ៖**

លោកប្រធាន អ្វីដែលខ្ញុំកំពុងសួរគឺ ខុសពីអ្វីដែលសហព្រះរាជអាជ្ញាបានធ្វើ។ សហព្រះរាជអាជ្ញា<ប្រើភស្តុតាងខ្លីៗដើម្បីបង្កើតគំរូមួយ ចំណែកខ្ញុំវិញត្រូវមើលបញ្ជីទាំងមូល ហើយបង្កើតជាភស្តុតាង>ថា តើមានអ្នកទោសប៉ុន្មាននាក់ដែលត្រូវគេចាប់មក<ដោយសារតែជា>ប្រពន្ធរបស់<អ្នកទោស ហើយយើងបានរកឃើញតួលេខហ្នឹងមក។ ដូច្នេះសរុបមក វាច្បាស់ណាស់ថា>តើខ្ញុំបានតួលេខមកពីណានោះ។ គឺខ្ញុំយល់ឃើញថា យើងកំពុងតែប្រើប្រាស់វិធីសួរនេះផ្សេងគ្នា <ប៉ុន្តែជាវិធីសាស្ត្រដែលអាចទទួលយកបានក្នុងការសួរទៅសាក្សីរូបនេះ>។ ដូច្នេះ សំណួរចុងក្រោយរបស់ខ្ញុំ គឺប្រាំភាគរយនៃអ្នកទោសត្រូវបានចាប់ខ្លួន គឺ ដោយសារតែការជាប់ពាក់ព័ន្ធនឹងសមាជិកគ្រួសារ អាចជាប្រពន្ធរបស់អ្នកទោសដែលគេចាប់មក។ <តើនេះជាតួលេខដែលស្របទៅនឹងការចងចាំរបស់លោកទេ? ខ្ញុំគិតថានេះជាសំណួរសមស្របអាចសួរបាន។>

[០៩:៣៥:០០]

**លោក ឌេល លីសាក់៖**

មានអ្នកទោសជាច្រើននៅក្នុងបញ្ជីនេះ <ដែលគេបាន>កំណត់ថា ជាកូន ជា<ម្ដាយ ជាឪពុក> ជាប្ដី។ ដូច្នេះគឺថា មានអ្នកទោសច្រើនណាស់ត្រូវបានគេកំណត់តាមរបៀបផ្សេងៗ ដែលត្រូវជាប់ពាក់ព័ន្ធទៅនឹងអ្នកដែលត្រូវគេចាប់ខ្លួនដទៃទៀត មិនមែនត្រឹមតែប្រពន្ធប៉ុណ្ណោះទេ។

**លោក វ៉ិចទ័រ កូប៉េះ៖**

ប្រសិនណាលោកមើលទៅ<តារាង*អ៊ិចសែល*>ឃើញថា ចំនួនតិចមែនទែន <គឺតិចជាងចំនួននេះឆ្ងាយណាស់។ នេះហើយជា>អ្វីដែលសហព្រះរាជអាជ្ញា<ធ្វើ គឺបង្កើត>ភស្តុតាង<តូចៗ នៅក្នុងអ្វីដែល>ទូទៅ។ ដូច្នេះ<ជាថ្មីម្ដងទៀត>ខ្ញុំ<នៅតែរក្សាសំណួររបស់ខ្ញុំដដែល។>

**ប្រធានអង្គជំនុំ៖**

សាក្សីឆ្លើយរួចហើយ ថាគាត់មិនអាចគណនាប៉ាន់ស្មានបានទេ ដោយហេតុផលពីរយ៉ាង ទី១ គឺមានការកំណត់នូវបញ្ជីរួមទូទៅ មិនបានឲ្យគាត់សិក្សាដើម្បីផ្អែកលើបញ្ជីដែលមានស្រាប់នោះ គណនាឡើងវិញអំពីភាគរយនៃប្រភេទមនុស្សទាំងឡាយដែលជាអ្នកទោសនៅមន្ទីរស-២១ឡើយ។ ទី២ ការប្រែប្រួលពីមួយម៉ឺនពីរពាន់ជាង រហូតមក មួយម៉ឺនប្រាំពាន់ជាងបច្ចុប្បន្ននេះ សាក្សីមិនបានទទួលព័ត៌មាន ឬក៏ពិនិត្យមើលឯកសារនោះទេ។ ដូច្នេះគាត់ឆ្លើយសំណួរនេះរួចហើយ សាក្សីមិនបាច់ឆ្លើយតបនូវសំណួរបែបនេះទៀតទេ។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ៖**

**ស៖** បាទ បើអ៊ីចឹងគឺខ្ញុំបន្តទៅមុខទៀត។ ឥឡូវខ្ញុំចូលសម្រង់លេខ១៤ គឺឯកសារ E3/455, អង់គ្លេស 00149913, ខ្មែរ 00146674, បារាំង 00149938។ លោកសាក្សី នៅក្នុងសម្រង់នេះ គឺសម្រង់លេខ១៤ ខ្ញុំសូមដកស្រង់សម្ដីរបស់លោក និយាយអំពីការបួមឈាមអ្នកទោស។ “នៅក្នុងភាពយន្ត រិទ្ធី ប៉ាន់ និងដីកាសន្និដ្ឋានបញ្ជូនរឿងស៊ើបសួររបស់សហព្រះរាជអាជ្ញា ខ្ញុំបានឃើញការបង្ហាញអំពីបញ្ហានេះ ប៉ុន្តែខ្ញុំមិនដែលអនុញ្ញាតឲ្យអ្នកណាម្នាក់បូមឈាមនោះទេ”។ ហើយនៅក្នុងឯកសារ E3/448 <ដែលជាសម្រង់ទី១៥>, អង់គ្លេស <00154912>, ខ្មែរ00154928, បារាំង 00154921 “ដូចដែលខ្ញុំបានបញ្ជាក់ហើយ ខ្ញុំមិនបានបដិសេធថា មិនមានការបូមឈាមនោះទេ ប៉ុន្តែខ្ញុំមិនបានឃើញដោយផ្ទាល់ភ្នែកខ្ញុំទេ”។ តើសម្រង់ទាំងពីរនេះត្រឹមត្រូវទេ លោកសាក្សី?

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន រឿងបូមឈាមនេះ ដំបូងខ្ញុំវង្វេង ហើយដល់ក្រោយមកបានវាឃើញទាំងផ្ទាំងទាំងមូលនៃបញ្ហានេះ។ បូមឈាមពីពេលណា ខ្ញុំអត់ចាំទេ ប៉ុន្តែអ្នកអនុញ្ញាត គឺខ្ញុំហើយនិងបង សុន សេន។ ហើយដល់ក្រោយមក ដល់បានការអនុញ្ញាតពីមេប៉ុណ្ណឹង មិត្តទ្រីទៅទាក់ទងនឹង មិត្តតៃ សុំយកស្អី ស៊ីត្រាតរបស់គេមក បូម។ រួចដល់ក្រោយមក ខាងមេប្រាប់ខ្ញុំថា មិត្តមើលណ៎ាប្រយ័ត្នដោយអាមេរោគ កាមរោគអីៗហ្នឹង។ ដូច្នេះ រឿងនេះវាទៅទាំងមូលគឺអ៊ីចឹង។ ឲ្យខ្ញុំទៅមើលគឺអត់បានមើលទេ។ ពីថ្ងៃណា ខែណា លើរូបអ្នកណា ខ្ញុំភ្លេចហើយ។ ក៏ប៉ុន្តែមេ ហើយនិងខ្ញុំ គឺបងសេន ហើយនិងខ្ញុំ គាត់ណែនាំមកខ្ញុំ។ រួចកិច្ចដំណើរការដល់ក្រោយមក គេទៅរលូនរបស់គេ រវាងមិត្តទ្រី ប្រធានពេទ្យស-២១ ហើយនិងមិត្តតៃ ប្រធានមន្ទីរពេទ្យព-៩៨។ នេះសូមបញ្ជាក់ប៉ុណ្ណឹង។ ព្រឹត្តិការណ៍ជាក់ស្តែងអ៊ីចឹង។ ការឆ្លើយកន្លងមកវាមានខ្វះខាតខ្លះ ស្អីខ្លះ ពិតមែន។

[០៩:៣៩:៣៥]

**ស៖** ខ្ញុំសូមសួរបញ្ជាក់ឲ្យច្បាស់លាស់ នៅក្នុងខ្សែភាពយន្ត រិទ្ធី ប៉ាន់ ដែលលោកបានឮអំពីរឿងរ៉ាវនៃការបូមឈាមពីអ្នកទោសនេះ <ជាលើកទី១>។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** រិទ្ធី ប៉ាន់ អ្នកសួរខ្ញុំទេ ខ្ញុំអ្នកឆ្លើយ។ មិនមែនខ្ញុំឃើញពីភាពយន្ត រិទ្ធី ប៉ាន់ ទេ គឺខ្ញុំអ្នកឆ្លើយ រិទ្ធី ប៉ាន់។

**ស៖** ឥឡូវ ខ្ញុំសូមចូលទៅប្រធានបទថ្មី ខ្ញុំសូមអានឲ្យលោកស្តាប់។

លោកប្រធាន គឺឯកសារ E3/226 នេះជាកំណត់ហេតុនៃកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍។ ខ្ញុំសូមបង្ហាញសម្រង់មួយជូនឲ្យសាក្សីមើលចេញពីកំណត់ហេតុនៃអង្គប្រជុំនេះ ខ្មែរគឺ 00017158, អង់គ្លេស 00183372, បារាំង 00296166។ បាទ ដូច្នេះ ខ្ញុំសូមការអនុញ្ញាតដើម្បីបង្ហាញសម្រង់នេះឲ្យសាក្សីពិនិត្យមើល។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

[០៩:៤១:១៧]

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01324191



**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សីនេះគឺជាកំណត់ហេតុនៃអង្គប្រជុំចុះថ្ងៃទី១០ មិថុនា ឆ្នាំ១៩៧៦ របស់គណៈអចិន្ត្រៃយ៍។ បាទ សូមលោកមើលត្រង់ផ្នែកដែលខ្ញុំ*ហាយឡាយ* ដែលនិយាយអំពីបញ្ហានៃការបរិច្ចាគឈាមហើយខ្ញុំសូមអានឲ្យលោកស្តាប់ដូចតទៅ ហើយខ្ញុំសួរមើលថា តើលោកយល់ឃើញដូចម្តេចដែរ? "បញ្ហានៃការបរិច្ចាគឈាម យើងប្រមូលកម្លាំងទូទៅ ដើម្បីឲ្យផ្តល់ឈាម ដើម្បីជួយសង្គ្រោះអាយុជីវិតកងទ័ពរបស់យើងដែលរៀបប្រយុទ្ធនៅតាមព្រំដែន។ បើបញ្ហានេះមិនអាចដោះស្រាយបាននៅ<តាមមូលដ្ឋានទេ វាគួរតែអាចដោះស្រាយបាននៅ>ភ្នំពេញ<>។ យើងនឹងប្រមូលកម្លាំងពីមន្ទីរ ក្រសួងនានា អង្គភាពនានាដើម្បីមកឲ្យផ្តល់ឈាម។ មានប្រជាជន<ជាង>មួយរយពាន់នាក់រស់នៅក្នុងទីក្រុងភ្នំពេញ យើង<អាច>បូមឈាម<ពីមនុស្ស៥.០០០នាក់>ជាប្រចាំខែ។ នៅក្នុងរយៈពេលយូរអង្វែង គឺថាយើងនឹងអាចប្រមូលឈាមបានច្រើន <ព្រោះយើងមានការផ្គត់ផ្គង់អាហារគ្រប់គ្រាន់>។ វិធីសាស្ត្រនេះ គឺយើងប្រមូល<អ្នកប្រយុទ្ធរបស់យើងទាំងបុរស ទាំងស្ត្រី>ពី<តាមមន្ទីរនិង>អង្គភាពកងទ័ព<នានា>។ <វាមិនបង្កើតបញ្ហាអីដល់យើងទេ វា>មិនមែនជាការ<>បូជាជីវិតអីធំដុំអីនោះទេ។" បញ្ចប់ការដកស្រង់។ លោកសាក្សី គណៈអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជាបាននិយាយអំពី<>គោលនយោបាយនៃការផ្តល់ឈាម <ជាមួយនឹងតំណាង>ក្រសួងសង្គមកិច្ចជាដើមនេះ។ តើ<នេះជាអ្វីដែល>លោក<> បាន<ដឹងនៅពេលនោះទេ គឺ>អំពីគោលនយោបាយស្តីអំពីការផ្តល់ឈាមនេះ<>?

[០៩:៤៣:២០]

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ ការប្រជុំនេះជាការប្រជុំផ្នែកខាងក្រសួងសង្គមកិច្ចនិងសុខាភិបាល អត់មានរឿងអីទាក់ទងនឹងស-២១ ទេ។ ស-២១ វាទទួលបញ្ជាពី៨៧០ តាមរយៈបង សុន សេន ដូច្នេះរឿងអនុវត្តជាក់ស្តែងវាវិវត្តន៍ទៅយ៉ាងណា ខ្ញុំបាននិយាយអស់ហើយ។ ដូច្នេះ រឿងកិច្ចការសង្គមកិច្ច និងសុខាភិបាល ជារឿងគេ ខ្ញុំយល់មិនដល់។

**ស៖** ខ្ញុំសូមសួរបញ្ជាក់ឲ្យច្បាស់ លោកជាមេបញ្ជាការវរសេនាធំដែលមានកម្លាំងកងទ័ពប្រហែលជា២.០០០នាក់។ តើត្រឹមត្រូវដែរឬទេដែលថា កម្លាំងកងទ័ពរបស់លោកនេះ កម្លាំងក្រោមការបញ្ជារបស់លោកក៏ត្រូវបានស្នើសុំឲ្យផ្តល់ឈាមដែរ ដើម្បីយកឈាមនេះទៅជួយទៅដល់យុទ្ធជននៅតាមព្រំដែន។ មានអ៊ីចឹងទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01324192



**ឆ៖** អរគុណ។ នៅស-២១ គ្មានការណែនាំពី៨៧០ តាមរយៈបង សុន សេន ឲ្យខ្ញុំបូមឈាមពីយុទ្ធជន កម្មាភិបាលរបស់ខ្ញុំទេ។ មានតែបូមឈាមពីអ្នកទោសដែលមានសុខភាពល្អ ជៀសវាងអាជំងឺកាមរោគ។

**ស៖** សូមអរគុណលោកសាក្សីខ្ញុំសូមចូលទៅប្រធានបទបន្ទាប់ទៀត។ ដើម្បីជាប្រតិចារឹកគឺនៅក្នុងបញ្ជីដែលថាមានអ្នកទោសរហូតទៅដល់ជាង ១៥.០០០នាក់នោះ <មាន>៧៩នាក់ត្រូវបានគេ <កំណត់ថា> ជាកូនស្រី ហើយ៣២នាក់<ជាប្តី> ៦១ជាកូនប្រុស ២៦គឺជាម្តាយ។ ដូចដែលខ្ញុំបានបញ្ជាក់ហើយ ចំនួននេះ គឺថាមានតួលេខនេះតិចតួចណាស់។ លោកសាក្សី ឥឡូវនេះយើងចូលទៅសម្រង់លេខ១៦ គឺឯកសារ E3/448, ERN អង់គ្លេស 00154912, ខ្មែរ 00154929, បារាំង 00154922។ លោកបានលើកឡើងអំពីសក្ខីកម្មនេះម្តងហើយម្តងទៀតនៅចំពោះមុខតុលាការ ដែលលោកបាននិយាយ<អំពី> នួន ជា <>បញ្ជាឲ្យលោក គឺថាធ្វើតេស្តថ្នាំពេទ្យ<ទៅលើជនរងគ្រោះ។ លោកនិយាយថា៖ “នួន ជា បានផ្តល់ថ្នាំ>ប្រមាណពី <២០> ទៅ ១៥ គ្រាប់ ដោយឲ្យខ្ញុំសាកថ្នាំនោះជាមួយជនរងគ្រោះរយៈពេលបីថ្ងៃ ហើយត្រូវរក្សាការសម្ងាត់។ តាមពិតទៅ ខ្ញុំបានដូរថ្នាំនោះដោយដាក់ម្សៅថ្នាប៉ារ៉ាសេតាម៉ុលជំនួសវិញ។” បាទ តើនេះ គឺជាសក្ខីកម្ម<ត្រឹមត្រូវ>ទេ លោកសាក្សី?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ប៉ុន្មានថ្ងៃមុននេះ ខ្ញុំនិយាយទៀតពីរឿងបងនួន ពូនួន ឲ្យថ្នាំខ្ញុំមកសាកពិសោធជាមួយអ្នកទោស គ្រាប់ថ្នាំចំនួនប៉ុន្មានខ្ញុំភ្លេចអស់ហើយ ប៉ុន្តែឯកសារនេះវាច្បាស់ ១៤, ១៥គ្រាប់ ហើយឲ្យពិសោធបីថ្ងៃ។ ដូច្នេះ រឿងរ៉ាវក្នុងនេះវាច្បាស់ជាង ខ្ញុំនៅចាំព្រឹត្តិការណ៍នេះ។ ដូច្នេះ ខ្ញុំសូមយកឯកសារនេះ ជាឯកសារប្រាកដប្រជា ច្បាស់លាស់ជាង។

[០៩:៤៨:១៨]

**ស៖** ឥឡូវនេះហាក់បីមាន<ភាព>ស្មុគស្មាញបន្តិចសម្រាប់ខ្ញុំ។ លោកសាក្សី លោកបានឆ្លើយថាលោកបានដូរថ្នាំហ្នឹង ដោយយកថ្នាំម្សៅប៉ារ៉ាសេតាម៉ុលមកជំនួសវិញ គឺដើម្បីសង្គ្រោះជីវិតរបស់អ្នកទោសនេះ។ តែទោះជាយ៉ាងណាក៏ដោយ លោកទទួលខុសត្រូវចំពោះការសម្លាប់អ្នកទោសទាំងអស់<នោះ។ ហើយជាការពិត> វន វ៉េត <ពេលដែលគាត់ចូលទៅស-២១ គាត់បានហៅលោកថា “អាឃាតករ”។> តើវាមានមូលហេតុអ្វីដែលនាំឲ្យលោកនេះ យកថ្នាំ ម្សៅថ្នាំប៉ារ៉ាសេតាម៉ុល មកជំនួសថ្នាំនេះ ដើម្បីសង្គ្រោះជីវិតអ្នកទោសនោះ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ការសួរបញ្ជាក់បែបនេះ ចៅក្រម ម៉ាកសែល

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ឡឺម៉ុងដ៍ សួរបញ្ជាក់ខ្ញុំ ខ្ញុំបានឆ្លើយថា ខ្ញុំមិនឲ្យដៃនេះ វាទៅសម្លាប់មនុស្សដោយផ្ទាល់ទេ។ អារឿង ស-២១ នេះ វាជាយន្តការកម្ទេចមនុស្សដែលគេបញ្ជូនមកឲ្យសួរចម្លើយ ហើយកម្ទេច ក៏ពិតមែន ក៏ប៉ុន្តែ ខ្ញុំមិនឲ្យដៃនេះវាទៅសម្លាប់មនុស្សដោយផ្ទាល់ទេ។ ខ្ញុំបានឆ្លើយជាមួយនឹងចៅក្រម ម៉ាក់សែល ឡឺម៉ុងដ៍ អ៊ីចឹង។

**ស៖** ខ្ញុំយល់ហើយថានេះគឺជាចម្លើយហើយ ក៏ប៉ុន្តែនៅពេលនោះ តើវាមានកត្តាអ្វីដែលនាំឲ្យលោកសម្រេចប្តូរថ្នាំបែបនេះ? ទោះជាលោកដូរ ឬមិនដូរក៏ដោយអ្នកទោសទាំងនេះក៏ត្រូវតែ មុខជានឹងស្លាប់ហើយ។ តើអ៊ីចឹងខ្ញុំសួរ កត្តាអ្វីដែលនាំឲ្យលោកដូរថ្នាំ?

[០៩:៥០:០០]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន កិច្ចដំណើរការនៅស-២១ ប្រធានស-២១ វាអត់ទៅធ្វើឃាតអ្នកទាំងអស់នោះដោយដៃវាផ្ទាល់ទេ វាមានយន្តការរបស់គេ អ្នកណាអ្នកកម្ទេច អ្នកណាវាអ្នកពិនិត្យឯកសារ អ្នកណារាយការណ៍ទៅខាងលើ វាមានយន្តការរបស់គេ វាមានភារកិច្ចរបស់គេច្បាស់លាស់។ ដូច្នេះ ប្រធាន ស-២១ វាអត់មានយន្តការទៅកម្ទេចមនុស្សដោយដៃវាទេ។ ប៉ុន្តែបណ្តាំពូនួន មិនឲ្យដោយខ្លួនឯង។ ដូច្នេះ ខ្ញុំ -- បើឲ្យដោយខ្លួងឯងវាទាល់តែប្តូរថ្នាំ កុំឲ្យអាដៃហ្នឹង វាទៅសម្លាប់មនុស្សដោយដៃវាផ្ទាល់។

**ស៖** មិនថ្វីទេ ឥឡូវនេះយើងចូលទៅប្រធានបទថ្មីមួយទៀត ហើយខ្ញុំយកសម្រង់ចេញពីសក្ខីកម្មរបស់លោក។ លោកសាក្សី នៅក្នុងកម្រងឲ្យជូនលោកនោះ គឺសម្រង់លេខ១៧, ១៨ និង១៩។ លោកប្រធាន នេះគឺជាឯកសារ E3/454, អង់គ្លេស 00147603, ខ្មែរ 00146661, បារាំង 00149924។ ឯកសារ <E3/449>, អង់គ្លេស 00159557, ខ្មែរ 00158840, បារាំង 00158848 និងឯកសារទី ៣ គឺឯកសារ E3/357, អង់គ្លេស 00242936, ខ្មែរ 00242925, បារាំង 00242947។ នេះគឺសម្រង់ចំនួនបីដែលខ្ញុំលើកយកមកសួរលោក លោកសាក្សី។<មាន>សំណួរ<មួយអំពី>ថាតើលោកបានឃើញ<ឧបករណ៍ធ្វើ>ទារុណកម្ម ដូចអ្នកដទៃបានឃើញនៅទួលស្លែងនោះដែរទេ <គឺអាងជ្រមុជទឹក។> ចម្លើយរបស់លោក៖ "ខ្ញុំមិនដែលឃើញអាងជ្រមុជទឹកនោះទេ។ ខ្ញុំបដិសេធដាច់ខាតនូវការនិយាយថាមានអាងជ្រមុជទឹកនេះ"។ នៅក្នុងសម្រង់ទី២ លោកនិយាយថា៖ "ខ្លួនខ្ញុំផ្ទាល់នោះ មិនដែលបានចូលទៅក្នុងបន្ទប់ធ្វើទារុណកម្ម ហើយមិនដែលឃើញក្តារខៀនពណ៌ខ្មៅ គេសរសេរអំពីវិធាននោះទេ។ ខ្ញុំ<ដឹង>ថា គេរកឃើញ<ការសរសេរអក្សរបែប>នេះនៅស-២១ ក៏ប៉ុន្តែ<តាមការយល់ឃើញរបស់

ខ្ញុំ>វាត្រូវបានគេសរសេរបន្ថែម ក្រោយថ្ងៃ០៧ មករា ១៩៧៩ ដោយហេតុផលនយោបាយ។ តែទោះជាយ៉ាងណាក៏ដោយ វាមិនមានមុនថ្ងៃ០៣ មករា ឆ្នាំ១៩៧៩នោះទេ។"

<ពាក់ព័ន្ធទៅនឹង>ឯកសារ<ពិសេសមួយ គឺចម្លើយសារភាព> លោកឃើញចំណាររអក្សររបស់ជនជាតិវៀតណាម <ហើយលោកថា> "ចំណាររនេះ គឺត្រូវបានសរសេរដោយជនជាតិវៀតណាមក្រោយ<>ឆ្នាំ១៩៧៩"។ លោកសាក្សី ចម្លើយទាំងបីនេះ គឺថា អ្វីៗជាក់លាក់ដែលយើងបានឃើញនៅស-២១ នៅទួលស្លែងសព្វថ្ងៃនេះ កាលពេលនោះ គឺថាមិនមាន មិនមានចំណុចទាំងអស់នេះទេ។ ត្រឹមត្រូវដែរទេ?

[០៩:៥៤:២៦]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន នៅស-២១ រហូតដល់ថ្ងៃ០៧ មករា គ្មានអាងជ្រមុជទឹក គ្មានអាគ្គារខៀន ហើយសរសេរស្អី "វិន័យសន្តិបាល" ដែលគេសរសេរជាអក្សរនេះ គ្មានទេ ហើយក៏គ្មានចំណាររបស់យួននៅលើឯកសាររបស់ស-២១ដែរ។ ហើយចំណែកឯកសារក្រោយមកនេះ វាមាន ហើយខ្ញុំបានបដិសេធហើយ នៅតែតាំងពីសម័យស៊ើបអង្កេតម្ល៉េះ ជាមួយសហ -- នៅសម័យស៊ើបអង្កេត ខ្ញុំបានបដិសេធអាស្អីវិន័យសន្តិបាលទាំង១០ខ។ ខ្ញុំថាមិនពិត។ ចៅក្រម ម៉ាកសែល ឡឺម៉ុងដ៍សួរខ្ញុំថា ម៉េចបានអ្នកឯងថាមិនពិត? ខ្ញុំថា អាចំណុចទី៨នោះ ដែលថា "កុំអាងយកស្អីកម្ពុជាក្រោមមកធ្វើជាលេស មិនឆ្លើយមិនបានទេ" ខ្ញុំថាគ្មានទេ។ ស-២១ អត់មែន មានណែនាំពីរឿងទឹកដីកម្ពុជាក្រោមទៅដល់អ្នកសួរទេ។ នេះជាគោលការណ៍ដែលខ្ញុំបដិសេធវិន័យសន្តិបាលទាំង១០ខ ដែលគេក្លែងក្លាយមកក្រោយនេះ នៅក្នុងសម័យដែលគេកសាងសារមន្ទីរទួលស្លែងស្អីគេនេះ។ ហើយអាអាងជ្រមុជទឹកអីហ្នឹង កុនប៊ីហ្សូ ថតទៅផ្សេងណា៎ ឯចំណែកអាអាងជ្រមុជទឹករបស់ ផា ថាចាន់ ឲ្យ វ៉ាន់ ណាត គូរនោះទៅផ្សេង។ តាមពិត វាគ្មានអាងជ្រមុជទឹកទេ។ ហើយជាក់ស្តែងមិនអីពិបាកយល់ទេ ចំណាររជាអក្សរយួននៅលើឯកសារស-២១ គឺចំណាររក្រោយ ០៧ មករា។

**ស៖** នៅក្នុងពេលលោកផ្តល់សក្ខីកម្ម--

**លោក ខេល លីសាក់៖**

បាទ ដើម្បីជាប្រតិចារឹក គឺមេធាវីមិនបានអានសម្រង់ជាចុងក្រោយពីឯកសារ E3/357 ទេ។ ចំណាររនេះ គឺជាអក្សររបស់អ្នកណាម្នាក់សរសេរនៅក្របខាងមុខនៃឯកសារនេះ ជាភាសាវៀតណាមថា "ចម្លើយសារភាព"។ អក្សរវៀតណាមនេះ គឺមានន័យតែប៉ុណ្ណោះឯង គឺ E3/357។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** បាទ នេះ គឺជាអ្វីដែលខ្ញុំបានអានហើយ ខ្ញុំមិនដឹងថា លោកព្រះរាជអាជ្ញារងអន្តរជាតិកត់សម្គាល់យ៉ាងដូចម្តេចនោះទេ។ ក៏ប៉ុន្តែលោកសាក្សី អ៊ីចេះ នៅក្នុងពេលលោកៗឆ្លើយទៅសំណួររបស់លោកចៅក្រម ឡាវ៉ែន៍ លោកបានបដិសេធពីបញ្ហាមួយចំនួន ដែលត្រូវបានគេយកមកបង្ហាញនូវក្នុងឯកសារភាពយន្ត<ឯកសារ>អាល្លឺម៉ង់<ខាងកើតឆ្នាំ១៩៨១> ហៅថា *"ឌិ<អង្គការ>"* នេះ គឺថាលោកបដិសេធ<>ថា <មិន>មានសញ្ញា<ស្វាគមន៍>មួយ<>នៅ<លើ>របង<ម្ខាង ដែលមាន>នៅក្នុងខ្សែភាពយន្តនេះ<ទេ។> ហើយលោកក៏បានបដិសេធអំពីអ្វីដែលគេថា មានការធ្វើការពិសោធថ្នាំពេទ្យ ដែលគេអានចេញមកពីកំណត់ត្រា អំពីការប្រើប្រាស់ថ្នាំពេទ្យ ហើយលោកប្រាប់ថា គេមានបន្លំ គេក្លែងៗទេ។ តើ<មានអ្វីផ្សេងទៀត ដែល>លោកយល់ថា នេះ គឺជាការក្លែងបន្លំឡើងពីសំណាក់វៀតណាមឬ?

[០៩:៥៨:១២]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! អញ្ជើញលោកសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

បាទ លោកប្រធាន យើង<អាចសួរដូច្នេះបាន បើ>មេធាវីការពារក្តីសួរតទៅទល់ជាមួយនឹងសាក្សី<ដោយ>យក ឯកសារមុនៗពាក់ព័ន្ធទៅនឹង<ខ្សែភាពយន្តនេះ ហើយអះអាងពីការក្លែងបន្លំ>ដែល<គាត់ផ្តល់លេខយោង>ឯកសារ និង ERN មកបញ្ជាក់ផង។

**លោក វ៉ិចទ័រ កូប៉េ៖**

សហព្រះរាជអាជ្ញានៅពេលនោះ ក៏មានវត្តមានក្នុងតុលាការដែរ ហើយនេះជាសំណួររបស់លោកចៅក្រម ឡាវ៉ែន៍ ទេ។

ឥឡូវទុកឯកសារខ្សែភាពយន្តរបស់អាល្លឺម៉ង់ខាងកើតនេះ ទាំងពីរនេះ ចោលចុះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី តើមានអ្វីផ្សេងទៀតដែលលោកគិតថា ជាការក្លែងបន្លំឡើងពីសំណាក់វៀត-ណាមក្រោយ ឆ្នាំ១៩៧៩?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្សែភាពយន្តអាល្លឺម៉ង់នេះ ខ្ញុំមិនដែលបានឃើញទេ ក៏ប៉ុន្តែគេនាំខ្ញុំទៅសារមន្ទីរទួលស្លែង អង្កាល់នោះ ចៅក្រម ម៉ាកសែល ឡឺម៉ុងដ៍ ហើយនិងឯកឧត្តម យូរ ប៊ុនឡេង។ ទៅដល់ ទៅឃើញអាងជ្រមុជទឹក ដែល ផា ថាចាន់ ហើយនិង វ៉ាន់ ណាតប្រឌិតឡើង។ ដែលខ្ញុំបដិសេធហ្នឹង បដិសេធអារឿងហ្នឹង។ ហើយខ្ញុំបដិសេធហ្នឹង បដិសេធជាមួយនឹងចៅក្រមស៊ើបអង្កេត មាន ម៉ាកសែល ឡឺម៉ុងដ៍ ហើយនិងឯកឧត្តម យូរ ប៊ុនឡេង។ អត់បានបដិសេធជាមួយនឹងលោកចៅក្រម ឡាវែន៍ ទេ។ នេះច្បាស់លាស់។ ឯចំណែក ខ្ញុំយកគោលគំនិតបដិសេធនេះ ខ្សែភាពយន្តអាល្លឺម៉ង់ណា ខ្ញុំសូមបញ្ជាក់ថា ខ្ញុំអត់ដែលបានមើលភាពយន្តអាល្លឺម៉ង់ទេ។ ហើយខ្ញុំសូមនិយាយបន្តិច អំពីខ្សែភាពយន្តដែលគេក្លែងបន្លំ។ ខ្សែភាពយន្តដែលគេក្លែងបន្លំ គឺខ្សែភាពយន្ត ហ៊ូ វ៉ាន់ តាយ បញ្ជូនជូនតុលាការ។ ដល់ក្រោយមក ហ៊ូ វ៉ាន់ តាយ ខ្លួនឯងសុខចិត្តដកឯកសារនេះទៅវិញ ក៏ប៉ុន្តែអង្គជំនុំជម្រះយកមកសួរ។ អង្កាល់នោះ លោកជំទាវ ខាតរាយធ៍ ថា គាត់ខំបញ្ចាំងរូបអាកូនក្មេងម្នាក់ស្រាតពងក្ដនលល។ គាត់សួរ អ្នកណានេះ? ខ្ញុំសង្កេតមើលមុខជនរងគ្រោះនោះ ខ្ញុំឆ្ងល់។ បានដល់ចុងបញ្ចប់ ខ្ញុំថា សូមឲ្យការិយាល័យសហព្រះរាជអាជ្ញារកសាលកបត្រស-២១ មកឲ្យខ្ញុំ បញ្ជាក់អំពីម្ដាយនង ចាន់ផល នេះ។ ឈប់ថ្ងៃសម្រាក ដល់ចូលមក កាលនោះព្រះរាជអាជ្ញាខ្មែរ តាន់ សេណារ៉ុង យកសាលកបត្ររបស់ស-២១មកបង្ហាញពិត ឃើញថាម្ដាយរបស់ នង ចាន់ផល ឈ្មោះអ្នកមីង មុំ យ៉ូវ ត្រូវបានចាប់មកនៅស-២១ មែន។ ខ្ញុំថា សុំទោស នង ចាន់ផល។ អ្នកឯងពិតជាមានតួនាទីនៅក្នុងកុនហ្នឹងមែន។ អ្នក -- ខ្ញុំទទួលស្គាល់ថា អ្នកឯងកំព្រាអត់ម៉ែ អត់ឪមែន។ ម៉ែឪអ្នកឯងទៅស្លាប់នៅស-២១មែន។ នេះឯចំណែកកុនរបស់ ហ៊ូ វ៉ាន់ តាយ ធ្វើហ្នឹងគឺជាការក្លែងបន្លំ។ ដូច្នេះអរគុណហើយ សូមចប់។

[១០:០១:៥៧]

**ស៖** លោកប្រធាន យើងខ្ញុំសុំការអនុញ្ញាតចូលទៅប្រធានបទមួយថ្មីទៀត។ ហើយខ្ញុំព្យាយាមបញ្ចប់ទៅដល់ពេលឈប់សម្រាកនេះ។ បាទ សុំមើលសម្រង់២១ និង ២៣ លោកសាក្សី។ <២១> គឺ E3/10590, អង់គ្លេស 00329123, ខ្មែរ <00095702> ដល់ <703>។

**អ្នកបកប្រែ៖**

សុំអធ្យាស្រ័យ លោកប្រធាន ញាប់ តាមមិនទាន់ទេ។

**ប្រធានអង្គជំនុំ៖**

សាឡើងវិញ លោកវ៉ិចទ័រ កូប៉េ អាននូវលេខERN សាជាថ្មីឡើងវិញទាំងអស់។ អ្នកបកប្រែបកមិនទាន់ទេ។

[១០:០២:៥០]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

តាមការពិត ខ្ញុំបានផ្ដល់ឯកសារទៅឲ្យអ្នកបកប្រែគឺ<>ឯកសារខ្ញុំបង់លេខ២១ និង២៣។ ឥឡូវចាប់ផ្ដល់លេខ២៣ គឺ E3/82, អង់គ្លេស 00398187, ខ្មែរ 00398179, បារាំង 00398193។ នេះគឺនិយាយអំពី នួន ជា និង តាម៉ុក។ ចម្លើយរបស់លោកមួយដែលឆ្លើយជូនតុលាការយោធា ហើយចម្លើយមួយទៀតឆ្លើយជូនសហចៅក្រមស៊ើបអង្កេត។ នៅក្នុងចម្លើយរបស់លោក ចំពោះមុខតុលាការយោធា លោកបានឆ្លើយថា នួន ជា ជាបុគ្គលទី៣ បាទ នួន ជា ជាជនទី៣។ ចំពោះ តាម៉ុក វិញ គឺថា នៅពីខាងក្រោយខ្នង ប៉ុល ពត រហូត ហើយជាអ្នកញុះញង់ ប៉ុល ពត។ ឥឡូវនេះ ខ្ញុំសូមបញ្ជាក់ឲ្យឃើញថា តាម៉ុក គឺជាអ្នកអនុវត្តរបបប្រល័យពូជសាសន៍ហើយ"។ ហើយនៅក្នុងកំណត់ហេតុស្ដាប់ចម្លើយមួយផ្សេងទៀតរបស់លោក លោកថានិយាយអំពីថា "<ខ្ញុំកត់សម្គាល់ឃើញថា មានការនិយាយអំពី>អ៊ំទី២ ពីព្រោះថា នៅស-២១ <យើង>មិនដែលហៅគាត់ថា ចំឈ្មោះទេ គឺ<យើង>ហៅថា បងទី២"។ នៅក្នុងឯកសារមួយនោះ លោកហាក់បីដូចនិយាយថា នួន ជា គឺជាជនទី៣។ ឯមកក្នុងឯកសារកំណត់ហេតុស្ដាប់ចម្លើយ លោកថា នួន ជា ជាបុគ្គលទី២។ តើមូលហេតុអី បានជាម្ដងថាគាត់ជាបុគ្គលទី៣ ម្ដងថា បុគ្គលទី២?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ឯកសារហ្នឹងវាពិតមែនអ៊ីចឹង ឯកសារមួយដែលគេថា បង -- ពូនួន នេះជាបុគ្គលទី៣។ ឯចំណែកឯកសារដែលជាកំណត់ហេតុសួរចម្លើយនៅ អ.វ.ត.ក យើងនេះ កំណត់ហេតុកាលសម័យស៊ើបអង្កេតនេះ ខ្ញុំឆ្លើយថា ពូនួន ជាបងទី២។ សូមជម្រាបបញ្ជាក់ថា ការពិតគឺអ្វី? ការពិតខ្ញុំនិយាយជាហូរហែមក អចិន្ត្រៃយ៍មជ្ឈិមបក្សមានប្រាំពីរនាក់។ បងប៉ុលជាទី១, បងនួន ជាទី២, បងនួន ជា -- អគ្គលេខា អ៊ំនែ! រង ជាលេខាធិការរងទី១ ជាអនុលេខាធិការទី១ ខ្ញុំបញ្ជាក់ជាហូរហែអ៊ីចឹង។ ដូច្នេះ ខ្ញុំគិតថាចម្លើយដែលមាននៅក្នុងនេះ ខ្ញុំគិតថាអាចខ្ញុំច្រឡំ តែករណីមួយហ្នឹង ក្នុងចំណោមករណីរាប់សិបរាប់រយករណីដែលខ្ញុំឆ្លើយជូនតុលាការ។ ខ្ញុំមិនដែលទទួលស្គាល់

ម្តងណាថា ពូនួន ជាបុគ្គលទី៣ទេ ការពិត ពូនួន ជាបុគ្គលទី២។ នេះគឺបញ្ជាក់អ៊ីចឹង។

**ស៖** ខ្ញុំសួរតពីបញ្ហានេះ លោកហៅ នួន ជា ថាបងទី២។ តើលោកបានដឹងថាមានឯកសារណាមួយ ថាឯកសារអ្វីក៏ដោយជាសារទូរលេខ ឬក៏ឯកសារទង់បដិវត្ត ឬក៏កំណត់ហេតុអង្គប្រជុំ ឬក៏ឯកសារណាមួយពីកម្ពុជាប្រជាធិបតេយ្យ ដែលកំណត់ថាលោក នួន ជា ជាបងទី២ ដែរឬទេ?

[១០:០៧:០៣]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន គ្មានទង់បដិវត្ត គ្មានការប្រជុំឯណាមកនេះទេ សរសេរថារបស់ ពូនួន ជាបងទី២ ទេ។ ពាក្យនេះដើមឡើយគឺ កុយ ធួន គាត់សរសេរ បងទី១ បងទី២។ ជាទូទៅ មុនដំបូងយើងខ្ញុំមិនដែលឮពាក្យហ្នឹងទេ។ ឮតែគេហៅ បងប៉ុល បងនួន – បងប៉ុល បងនួន។ នៅខាងយោធា គេហៅ បងខៀវ គេហៅ បង៨៩ ឬគេហៅ បងហុកសិប-- ដោយឡែក ស-២១ វាហៅ “បង៦២” វាមានការសន្មតអ៊ីចឹង។ ដល់ពេលដែល កុយ ធួន គាត់ឆ្លើយ គាត់លេងបងទី១ បងទី២។ ប៉ុល ពត ក៏យល់ស្របតាមការហៅហ្នឹងដែរ។ បានជាខ្ញុំនិយាយថាយល់ស្រប នៅពេលដែលធ្វើបុណ្យ ១៧ មេសា ឆ្នាំណាទេ គាត់និយាយថា “គោលបំណងរបស់ អាយួន សំខាន់គឺអាទី១ និងអាទី២ កម្ចាត់អាទី១ និងអាទី២” នេះសម្តី បងពត – បងប៉ុល នៅក្នុងពិធីបុណ្យហ្នឹង។ ហើយដល់ក្រោយមកទៀត ស្រាប់តែឮ បងខៀវ –បងសុន សេន– ណែនាំខ្ញុំថា “ឌុច អ្ហា! ស-២១ នាំអាទីគេហៅ បងទី១ ទី២” ខ្ញុំមិនមាត់ អាហៅបងទី១ ទី២ យួនតើ។ របបវាអាទី១ វាធំជាងអាទី២។ តាមពិតនៅក្នុងបក្សកុម្មុយនីស្តកម្ពុជាហ្នឹងក៏ដោយ ទី៦ បងវន ក៏ធំជាង បងខៀវ ទី៧ ដែរ។ ទំនាស់គ្នាក្នុងរឿងក្រណាត់អាវអាពួកអាវពណ៌នេះហ្នឹង។ ប៉ុនដល់ក្រោយមក មិនដឹងគាត់យល់ឃើញយ៉ាងម៉េច ទាំង បងប៉ុល, ទាំង ពូនួន នេះណែនាំមិនឲ្យប្រើពាក្យបងទី១ ទី២។ ដូច្នេះ អ្នកនាំអាទីប្រើពាក្យបងទី១ ទី២ គឺនៅស-២១ គឺ កុយ ធួន ចម្លើយបង កុយ ធួន។ ឯចំណែក រឿងនេះនៅក្នុងបក្សកុម្មុយនីស្តកម្ពុជាក៏ធ្លាប់មានប្រើយ៉ាងហ្នឹងដែរ។ អង្គាល់ពីសវនាការសក្ខីកម្មលើកមុន សុន អរុណ សួរខ្ញុំ។ ខ្ញុំថាអាណាទៅកាប់គេ បើយុទ្ធជនគេហៅខ្ញុំ បងឯកើត ហៅមិត្តហ៊ បងឯលិច។ អាហ្នឹងយុទ្ធគេហៅតើ អាហ្នឹងយើងនិយាយគ្នាឲ្យច្បាស់។ ដូច្នេះ បងទី១ ទី២ នេះខ្ញុំជម្រាបបញ្ជាក់ ទី១ អារឿងទី១ ទី២ នេះ គឺ កុយ ធួន ជាអ្នកនាំអាទីមុនគេ។ ដូច្នេះវា រាលដាលដល់ស-២១ ហើយនៅខាងក្រៅទៀត ខ្ញុំមិនដឹងទេ។ ការដែលហៅ ទី១ ទី២នេះ ក្នុងពិធីបុណ្យមួយនោះ បងប៉ុល គាត់យល់ស្រប។ សុន្ទរកថាគាត់អាចទុកជាភស្តុតាងដល់យើង។ ប៉ុន្តែដល់ក្រោយមកណែនាំ ខាងលើណែនាំឲ្យឈប់ប្រើពាក្យហ្នឹង ព្រោះវាយួន មានលក្ខណៈយួន ក៏ប៉ុន្តែក្នុងបក្សទាំង

អស់ ទី១ វាធំជាងទី២។ លក្ខន្តិកៈបក្ស ភាគតិចគោរពភាគច្រើន ថ្នាក់ក្រោមគោរពថ្នាក់លើ ទូទាំងប្រទេសគោរពមជ្ឈិមបក្ស។ នេះអ៊ីចឹង។ ខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង។

**ស៖** សូមអរគុណលោកសាក្សី។

**លោក វ៉ិចទ័រ កូប៉េះ៖**

លោកប្រធាន ក្នុង -- ដោយសារថាមានការជំទាស់ជាច្រើន ខ្ញុំត្រូវការ៣០នាទីទៀត ហើយខ្ញុំសុំអនុញ្ញាតក្រោយពីសម្រាកខ្ញុំអាចនឹងបញ្ចប់អ្វីៗដែលខ្ញុំនៅសេសសល់ បាទ។

**ប្រធានអង្គជំនុំ៖**

មិនអនុញ្ញាតឲ្យទេ លោកប្រើប្រាស់ពេលវេលាលើសហើយ គឺមានតែ៤៥នាទីប៉ុណ្ណោះ យើងឲ្យរហូតដល់ទៅ គ្រប់ពេញពេលហើយ ទោះបីជាមានការយឺតក្នុងរយៈពេល១០នាទីដំបូងនៃកិច្ចបំពេញនីតិវិធីក៏ដោយ។

បាទ អង្គជំនុំជម្រះអរគុណលោក កាំង ហ្កេកអ៊ាវ ហើយសវនាការស្តាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សីដល់ពេលនេះ ដល់ទីបញ្ចប់ហើយ ហើយសក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានសំខាន់ក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ។ ហើយវត្តមានរបស់លោកនៅ អ.វ.ត.ក នេះ លែងមានភាពចាំបាច់ទៀតហើយ សូមលោកមានសុខភាពល្អ ហើយមានអាយុយឺនយូរ ហើយនិងបានសេចក្តីសុខ។ ហើយបង្គាប់ឲ្យអនុរក្ស -- មន្ត្រីរដ្ឋបាលតុលាការរួមជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ រួមនិងអនុរក្សមន្ទីរឃុំឃាំង អ.វ.ត.ក សហការ និងសម្របសម្រួលជាមួយនឹងអនុរក្សពន្ធនាគារខេត្តកណ្តាល បញ្ជូនលោក កាំង ហ្កេកអ៊ាវ ទៅកាន់ពន្ធនាគារខេត្តកណ្តាលវិញចុះ។

លោកសាក្សីលោកអាចអញ្ជើញចាកចេញបានហើយ។

*(សាក្សីចាកចេញពីបន្ទប់សវនាការ)*

[១០:១២:៣៦]

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះធ្វើនីតិវិធីនៃការស្តាប់នូវសារណាផ្ទាល់មាត់លើភាគីរបស់ភាគីលើសំណើសុំរបស់សហមេធាវីការពារ ខៀវ សំផន លើឯកសារ E420 ហើយអង្គជំនុំជម្រះសូមរំឭកថា កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦ អង្គជំនុំជម្រះបានទទួលនូវការជូនដំណឹងក្រៅផ្លូវការមួយតាមរយៈអ៊ីម៉ែលពីក្រុមសហមេធាវីការពារក្តី ខៀវ សំផន ដោយភ្ជាប់ជាមួយនឹងសំណើដែលមានជាភាសាបារាំងតែមួយ។ ហើយមេធាវីការពារក្តីបានបញ្ជាក់ថា ដោយសារតែមានភាពបន្ទាន់នៃបញ្ហា មេធាវី

សម្រេចបញ្ជូនសំណៅនៃភាសា -- នៃពាក្យសុំជាភាសាបារាំងមកអង្គជំនុំជម្រះ និងភាគីជ្រាបជាមុន ហើយមេធាវី និងដាក់សំណើសុំផ្លូវការនៅពេលដែលខ្លួនទទួលបានការបកប្រែជាភាសាខ្មែររួចរាល់។ ហើយនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៦ នៅវេលាល្ងាចចុងម៉ោង អង្គជំនុំជម្រះបានទទួលសំណើនេះជាផ្លូវការដែលមានជាភាសាខ្មែរ និងជាភាសាបារាំង ហើយនៅក្នុងសំណើនោះ មេធាវីការពារក្តី នួន ជា បានមានការព្រួយបារម្ភពីភាពមិនច្បាស់លាស់លើវិសាលភាពខ្លះនៃអង្គហេតុនៃការបោសសម្អាតផ្ទៃក្នុង ជាពិសេសមេធាវីការពារក្តីបានស្នើដល់អង្គជំនុំជម្រះឲ្យពិចារណាឡើងវិញ ចំពោះសាក្សីមួយចំនួនដែលអង្គជំនុំជម្រះបានសម្រេចកោះហៅពាក់ព័ន្ធនឹងអង្គហេតុនេះ រួមទាំងដើមបណ្តឹងរដ្ឋប្បវេណីមួយរូបដែលនឹងត្រូវមកផ្តល់សក្ខីកម្មនៅថ្ងៃនេះផងដែរ។

ដោយផ្អែកលើសេចក្តីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាដំណោះស្រាយ មេធាវីការពារក្តីអះអាងថា ក្រៅពីអង្គហេតុនៃការបោសសម្អាតនៅតាមទីតាំងផ្សេងទៀត អង្គជំនុំជម្រះមានយុត្តាធិការពេលវេលា និងដែនដីកម្រិតត្រឹមតែអង្គហេតុនៃបោសសម្អាតផ្ទៃក្នុងនៅភូមិភាគឧត្តរចាស់ គឺភូមិភាគកណ្តាល ហើយនិងភូមិភាគឧត្តរថ្មី ក្នុងឆ្នាំ១៩៧៦ និងនៅភូមិភាគបូព៌ាក្នុងឆ្នាំ១៩៧៨ ប៉ុណ្ណោះ។ ហើយដើម្បីដោះស្រាយបញ្ហានេះ ឲ្យបានឆាប់មុន ពេលត្រូវបានសម្រេចថាតើត្រូវស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញលើអង្គហេតុនេះ ឬក៏ត្រូវពន្យារពេលសិនឬយ៉ាងណានោះ អង្គជំនុំជម្រះសាលាដំបូង កាលពីថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៦ បានជូនដំណឹងដល់ភាគីនានា អំពីចេតនាក្នុងការស្តាប់សារណាផ្ទាល់មាត់របស់ភាគី លើសំណើរសុំបន្ទាន់របស់ក្រុមមេធាវីការពារក្តី ខៀវ សំផន នៅថ្ងៃនេះ ហើយបន្ទាប់ពីការចប់ការស្តាប់សក្ខីកម្មសាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច។ ហើយដោយសារតែសំណើសុំរបស់មេធាវីការពារក្តី ខៀវ សំផន ជាផ្លូវការដែលមានពីរភាសា ហើយទើបតែដាក់មកអង្គជំនុំកាលពីល្ងាចថ្ងៃសុក្រទី២៤ ខែមិថុនា ឆ្នាំ២០១៦ ហេតុដូច្នេះ អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តី ខៀវ សំផន ដើម្បីធ្វើការបង្ហាញដោយសង្ខេប នូវសំណើសុំរបស់ខ្លួនជាមុនសិន មុននឹងផ្តល់វេទិកាជូនទៅភាគីដទៃទៀត ដើម្បីឆ្លើយតបទៅនឹងសារណានៃសំណើសុំរបស់ខ្លួន។

បានសុំអញ្ជើញក្រុមសហមេធាវីការពារក្តី លោក ខៀវ សំផន!

[១០:១៥:៥៨]

**កញ្ញា អង់តា ហ្គីសសេះ**

សូមគោរពលោកប្រធាន លោក លោកស្រី ចៅក្រម។ សូមអរគុណច្រើនលោកប្រធាន ខ្ញុំនឹង

សង្ខេបអំពីសំណើរបស់យើងខ្ញុំ។ ខ្ញុំសូមបញ្ជាក់ផងដែរថា សំណើរបស់យើងនេះ មិនមែនជាសំណើឲ្យសុំពិចារណាឡើងវិញទេ គ្រាន់តែជាសំណើសុំឲ្យមានការបំភ្លឺ ឲ្យច្បាស់ក្រោយពីមានការសម្រេចកាលពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៦ របស់អង្គជំនុំជម្រះ ដែលអង្គជំនុំជម្រះបញ្ជាក់ថាខ្លួនចង់ស្ដាប់សក្ខីកម្មរបស់ 2-TCW-1005 ជាសាក្សីដែលត្រូវបានសហព្រះរាជអាជ្ញាស្នើសុំ។ យើង<>បានជំទាស់ទៅនឹង<វត្តមានរបស់សាក្សីរូបនេះ ព្រោះថា>សក្ខីកម្មរបស់សាក្សីរូបនេះ<>មិនពាក់ព័ន្ធទៅនឹងវិសាលភាពនៃសំណុំរឿង០០២/០២ <ទេ>។ អង្គជំនុំជម្រះបាន<ផ្អែកទៅលើមូលហេតុរបស់សហព្រះរាជអាជ្ញា>ថា សក្ខីកម្មរបស់សាក្សីរូបនេះ ស្ថិតនៅក្នុងវិសាលភាព ពីព្រោះថា សាក្សីរូបនេះនឹងនិយាយអំពីការបោសសម្អាតនៅក្រចេះ<>។ យោងតាមសំអាងហេតុរបស់អង្គជំនុំជម្រះនេះ វាមានបញ្ហាចោទឡើងថាតើអង្គជំនុំជម្រះចង់បានអ្វី ចង់មានន័យថាម៉េច ពាក់ព័ន្ធទៅនឹងការប្ដឹងអំពីការបោសសម្អាតផ្ទៃក្នុងនេះ ពីព្រោះយើងក្រោយពីបានវិភាគទៅ យើងឃើញថា យើងចូលទៅក្នុងសេចក្ដីលម្អិត ពាក់ព័ន្ធទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះនឹងដីកាដំណោះស្រាយ និងជាពិសេស គឺសេចក្ដីសម្រេចអំពីការបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះនៅឆ្នាំ២០១៤។

ក្រោយពីការវិភាគទៅលើឯកសារទាំងអស់ ខ្ញុំដូចជាមិនយល់ ថាតើហេតុអ្វីបានជាអង្គជំនុំជម្រះអាចចេញសំអាងហេតុរបស់ខ្លួននៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៦ យ៉ាងម៉េចកើត ដោយខ្លួនលើកឡើងថា សក្ខីកម្មនោះនឹងនិយាយអំពីការបោសសម្អាតនៅក្នុងតំបន់ក្រចេះ ជាតំបន់ឯករាជ្យ<៥០៥> ដែលវាមិនស្ថិតនៅក្នុងភូមិសាស្ត្រ ដែលមានចែងនៅក្នុងដីកាដំណោះស្រាយ និងនៅក្នុងអត្ថបទច្បាប់ផ្សេងទៀតទេ ដូច្នេះហើយ ខ្ញុំមិនយល់អំពីជំហររបស់អង្គជំនុំជម្រះ ហេតុនេះហើយបានជាខ្ញុំស្នើសុំឲ្យអង្គជំនុំជម្រះបំភ្លឺឲ្យបានច្បាស់ត្រង់ចំណុចនេះ។

[១០:១៨:៣៧]

យោងតាមវិធាន៩៨(២) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះអាចធ្វើការជំនុំជម្រះបានតែលើអង្គហេតុដែលមានចែងនៅក្នុងដីកា<បញ្ជូនរឿងទៅជំនុំជម្រះ>។ ដូច្នេះ យើងបានបញ្ជាក់នៅក្នុងឯកសាររបស់យើង E420 ដែល<យើងបាន>បង្ហាញ<លម្អិតអ្វីទាំងអស់ដែលមាននៅក្នុងសេចក្ដីផ្ដើមសារណានៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ កថាខណ្ឌដែលមាននៅក្នុង>ដីកាដំណោះស្រាយពាក់ព័ន្ធទៅនឹងការបោសសម្អាតផ្ទៃក្នុង<ត្រូវបានរៀបរាប់លម្អិត>។ ខ្ញុំចង់បញ្ជាក់ឲ្យបានច្បាស់ត្រង់ចំណុចនេះ ការបោសសម្អាតមិនមែនជាឧក្រិដ្ឋកម្មទេ ការបោសសម្អាតគ្រាន់តែជាពាក្យពេចន៍មួយ ដែលសហចៅក្រមស៊ើប

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

អង្កេតបានប្រើប្រាស់ក្នុងពេលដែលខ្លួនតាក់តែងដីកាដំណោះស្រាយរបស់ខ្លួន។

ដូច្នេះ ការបោសសម្អាតនេះ មិនមែនជាឧក្រិដ្ឋកម្មឯករាជ្យទេ គឺវាមានទំនាក់ទំនងជាមួយនឹងមន្ទីរសន្តិសុខណាមួយ ឬក៏មានទំនាក់ទំនងជាមួយនឹងទីតាំងសម្លាប់មនុស្សណាមួយ ដូចដែលយើងបានបញ្ជាក់នៅក្នុងសារណារបស់យើងជាលាយលក្ខណ៍អក្សររួចមកហើយ គឺវាពាក់ព័ន្ធទៅនឹងទីតាំង ដែលពាក់ព័ន្ធ ឧទាហរណ៍ដូចជាព្រលានយន្តហោះកំពង់ឆ្នាំង អូរកន្សែង ឬសហករណ៍ត្រាំកក់។ ខ្ញុំបានលើកឡើងនៅទីតាំងទាំងបីនេះជាពិសេស ពីព្រោះថា ខ្ញុំផ្តោតទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីដែលលើកឡើងអំពីទីតាំងទាំងអស់នេះ។ ដូច្នេះ នៅពេលដែលពិនិត្យមើលដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ និងជាពិសេសកថាខណ្ឌ៤២ និង៧១ នៃដីកាបញ្ជូនរឿងឲ្យជំនុំជម្រះនេះ យើងឃើញថា នៅក្នុងដីកាដំណោះស្រាយ គឺនៅក្នុងកថាខណ្ឌ១៩២ និងទៅដល់កថាខណ្ឌ២០៣ នៃដីកាដំណោះស្រាយ <ប៉ុន្តែការកំណត់ចរិតលក្ខណៈច្បាប់> យើងត្រូវអានដីកាដំណោះស្រាយនេះ អំពីអង្គហេតុឲ្យបានច្បាស់ ពិសេស ពាក់ព័ន្ធទៅនឹងការកំណត់ប្រភេទនៃបទល្មើស។ ដូច្នេះ បើយើងពិនិត្យមើលកថាខណ្ឌ<១៣៤៧> ទៅ១៥៧៦ <នៅពេលយើងអានឯកសារទាំងអស់នេះ> រួមទាំងកំណត់សម្គាល់ចុងទំព័រផងដែរនោះ ពាក់ព័ន្ធទៅនឹងការបោសសម្អាត យើងឃើញថាមានការ<ដាក់សេចក្តីសន្និដ្ឋានមួយ ដែលដាក់កំហិតទៅលើព្រឹត្តិការណ៍ដែលបានកើតឡើងនៅក្នុងភូមិភាគឧត្តរក្នុងឆ្នាំ១៩៧៦ និងព្រឹត្តការណ៍ដែលបានកើតឡើងនៅភូមិភាគបូព៌ាក្នុងឆ្នាំ១៩៧៨ ហើយដែលអង្គហេតុទាំងនោះ>ពាក់ព័ន្ធទៅនឹង<ស-២១ ឬ>ភ្នំក្រោលផងដែរ។

<ហើយដូចដែលខ្ញុំបាននិយាយពីខាងដើមរួចមកហើយ វគ្គផ្សេងៗទៀតនៅក្នុងដីកាដំណោះស្រាយពាក់ព័ន្ធទៅនឹងការបោសសម្អាត ហើយនិង>យោងទៅតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះស្តីពីការបំបែក កិច្ចដំណើរការនីតិវិធីនៅខែឧសភា ឆ្នាំ២០១៤ យើងមានទីតាំងបី ដែលអាចលើកឡើងអំពីការបោសសម្អាត គឺព្រលានយន្តហោះកំពង់ឆ្នាំង <កងពល៦២ នៅក្នុងឆ្នាំ១៩៧៦ និងឆ្នាំ១៩៧៧>។ នេះគឺនៅកថាខណ្ឌ<៣៨៧> នៃដីកាដំណោះស្រាយ។ យើងក៏មាននិយាយអំពីអូរកន្សែង ដែលនិយាយអំពីការបោសសម្អាត<កម្មាភិបាលថ្នាក់ក្រោម ហើយនិងកងទ័ពនៅក្នុង>កងពល<៨០១ នៅឆ្នាំ១៩៧៧ ដែលមាននៅក្នុងកថាខណ្ឌ ៦១៤ នៃដីកាដំណោះស្រាយ។> ហើយនិងនៅក្នុងសហករណ៍ត្រាំកក់ គឺវាអង្គហេតុពាក់ព័ន្ធទៅនឹងការប្រជុំនៅឆ្នាំ៧៧, ៧៨ ដែលលើកឡើងនៅក្នុងកថាខណ្ឌ<៣០៩> នៃដីកាដំណោះស្រាយ។ ខ្ញុំធ្វើសង្ខេបបែបនេះ ដោយខ្ញុំពន្យល់ឲ្យបានច្បាស់ ថាខ្ញុំយោងលម្អិតទៅនឹងសារណារ

ជាលាយលក្ខណ៍អក្សររបស់យើងខ្ញុំ។ ជាពិសេស គឺកំណត់សម្គាល់ជើងទំព័រផ្សេងៗ នៅក្នុងសារណាររបស់យើងខ្ញុំ ។

<ក្នុងករណីណាក៏ដោយ យុត្តាធិការរបស់>អង្គជំនុំជម្រះ<នេះ> គឺវាមិនអាចលើសអំពីចំណុចទាំងអស់នេះទេ។ ហេតុនេះហើយបានជាយើងធ្វើសំណើឲ្យមានការបំភ្លឺឲ្យបានច្បាស់ អំពីវិសាលភាពទាំងអស់នេះ ពីព្រោះថា វាកំណត់នូវលក្ខខណ្ឌនៃការសួរសំណួរទៅកាន់ភាគី ឬក៏ដើមបណ្ដឹងរដ្ឋប្បវេណីដែលត្រូវបានកោះហៅសម្រាប់វគ្គ<>នេះ យើងត្រូវការយល់ឲ្យបានច្បាស់ ថាតើ<ហេតុអ្វីបានជាយើងត្រូវធ្វើការវិភាគដីកាដំណោះស្រាយ និងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជាមួយនឹងគ្រប់កថាខណ្ឌដែលខ្ញុំបានលើកឡើងពីខាងដើម។ យើងចង់យល់ថា>តើអង្គជំនុំជម្រះចេញសំអាងហេតុយ៉ាងម៉េចបានក្នុងការកោះហៅសាក្សី1005។

[១០:២៣:២០]

<តើធ្វើម៉េចទើបអាចចាត់ទុកថាតំបន់ក្រចេះ ដែលអត់មាននៅក្នុងឯកសារតុលាការ> ដូចដែលខ្ញុំបានរំឭកអ៊ីចឹង ថាតើអង្គជំនុំជម្រះអាចគិតថា <ខ្លួនមានយុត្តាធិការទៅលើ>ការបោសសម្អាតនៅក្រចេះនេះយ៉ាងម៉េចបាន? នេះជាការព្រួយបារម្ភយ៉ាងសំខាន់ ព្រោះថាយើងបានបញ្ជាក់នៅក្នុងសារណាជាលាយលក្ខណ៍អក្សរមកហើយថា នៅពេលដែលយើងពិនិត្យមើលបញ្ជីសាក្សី ដែលអង្គជំនុំជម្រះចង់កោះមកហៅពាក់ព័ន្ធនឹងការបោសសម្អាត<>នេះ។ <នៅពេលដែល>យើង<ដឹង>ថា មានសាក្សីបីរូបតែប៉ុណ្ណោះ<ក្នុងចំណោមសាក្សីប្រាំមួយនាក់> ហើយនិងដើមបណ្ដឹងរដ្ឋប្បវេណីមួយ<ចំនួនដែលត្រូវបានកោះហៅ -- យើងមានតែសាក្សីបីនាក់>ដែលត្រូវបានបញ្ជាក់នៅក្នុងដីកាដំណោះស្រាយនៅក្នុងសំណុំរឿង០០២។ ហើយសាក្សីផ្សេងទៀត ជាពិសេស គឺចម្លើយជាច្រើនពីមុនរបស់សាក្សីទាំងអស់នេះដែលអង្គជំនុំជម្រះគិតថា វាមិនមានភាពពាក់ព័ន្ធនៅក្នុងការបោសសម្អាតនេះ គឺវាចេញមកពីសំណុំរឿងផ្សេង ដែលកំពុងតែស៊ើបអង្កេត គឺសំណុំរឿង០០៣ និងសំណុំរឿង០០៤។ <ហើយយើងក៏បាននិយាយអំពីអ្វី>ដែលយើងភ័យខ្លាចតាំងពីដំបូង<រួចមកហើយ ដោយការណែនាំកត្តាសំខាន់ៗមកពី>សំណុំរឿងផ្សេង<ទៀត> មកបំពេញ <ឬបញ្ជាក់>លើសំណុំរឿងរបស់យើងនោះ <យើងឃើញថា យុត្តាធិការរបស់តុលាការនេះពិត>ជា<បាន>ពង្រីក <ដែល>មិនស្របទៅនឹងវិធាន៩៨(២)ទេ។ ហើយ<ធាតុផ្សំផ្សេងទៀតដែលខ្ញុំបានបញ្ជាក់រួចមកហើយពីខាងលើនោះ គឺអ្វីដែលមាននៅក្នុងដីកាដំណោះស្រាយហើយនិងមូលដ្ឋាននៃយុត្តាធិការរបស់>អង្គជំនុំជម្រះ<>។ ដូច្នេះ ខ្ញុំគិតថានេះ វាជាបញ្ហាស្មុគស្មាញ

<ក្នុងការសង្ខេបក្នុងរយៈពេលខ្លីបែបនេះ> ក៏ប៉ុន្តែអ្វីដែលយើងចង់ដឹងច្បាស់នោះ<គឺ>ថា តើ<អ្វីដែល>អង្គជំនុំជម្រះ<ចាត់ទុកថាជាវិសាលភាពនៃយុត្តាធិការរបស់ខ្លួន>? <លោក លោកស្រីចៅក្រមបានដឹងពីទស្សនៈរបស់យើង ពី>ការយល់<ឃើញរបស់យើងហើយ ចំពោះអ្វីដែលជាយុត្តាធិការរបស់តុលាការនោះ ហើយនៅពេលដែលយើងមើលទៅលើ>ឧបសម្ព័ន្ធទៅនឹងដីកាសម្រេចស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធីនោះ <វាហាក់ដូចជា>ថា អង្គជំនុំជម្រះ<យល់ពីស្ថានការណ៍ដូចយើងខ្ញុំដែរ។ ប៉ុន្តែ>នៅពេលដែលយើងពិនិត្យមើលសំអាងហេតុដែលអង្គជំនុំជម្រះចេញ <កាលពីពេលថ្មីៗនេះ>ពាក់ព័ន្ធទៅនឹងសាក្សី 2-TCW-1005 នេះ វា<ធ្វើឱ្យមានចម្ងល់>។ ខ្ញុំនិយាយតែចំពោះសាក្សី<2-TCW-1005>នេះទេ <ព្រោះថា>សាក្សីផ្សេងៗទៀត ដែលមាន<បញ្ជាក់>នៅក្នុង<ញត្តិ យើងបានសង្ខេបរួចហើយនូវអ្វីដែលយើងរំពឹងទុកពីការធ្វើសក្ខីកម្មរបស់ពួកគេ ក៏ប៉ុន្តែយើងនៅតែមិនទាន់>មានហេតុផលជាក់លាក់<របស់អង្គជំនុំជម្រះ បញ្ជាក់ពីហេតុផល>ក្នុងការកោះហៅសាក្សីទាំងអស់នេះ។ ខ្ញុំមិនអាច<និយាយ>ឱ្យបានច្បាស់<អំពីមូលហេតុ>របស់អង្គជំនុំជម្រះក្នុងការកោះហៅសាក្សីទាំងអស់នេះទេ។ ក៏ប៉ុន្តែចំពោះយើង គឺច្បាស់ណាស់ថា <យុត្តាធិការ>នៃអង្គជំនុំជម្រះ គឺអង្គហេតុនៅក្នុងភូមិភាគឧត្តរ<ក្នុងឆ្នាំ១៩៧៦> ភូមិភាគបូព៌ា<ក្នុងឆ្នាំ១៩៧៨> និងអ្វីដែលពាក់ព័ន្ធទៅនឹងស-២១ ដូចជាភ្នំក្រោល និងទីតាំងផ្សេងទៀត ដូចដែលអ្វីដែលខ្ញុំបានបញ្ជាក់ជូនមុននេះ គឺវាពាក់ព័ន្ធទៅនឹងទីតាំងដែលអង្គជំនុំជម្រះយល់ថា ស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ស្របតាមដីកាបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង។

[១០:២៦:៣៤]

ដូច្នេះ យើងខ្ញុំមានភាព<ស្ទាក់ស្ទើរ និង>ព្រួយបារម្ភ <ក្នុងការប្រឈមទៅនឹងអ្វីដែលយើងគិតថាជា>ការពង្រីកវិសាលភាព<យុត្តាធិការរបស់អង្គជំនុំជម្រះ> បើធៀបទៅនឹងអ្វីដែលបានកំណត់នៅក្នុងដីកាដំណោះស្រាយ។ នេះជាការសង្ខេបអំពីគោលជំហររបស់យើង<> ហើយនិង<មូលហេតុ>ដែលយើង<>ស្នើសុំទៅអង្គជំនុំជម្រះ ឱ្យបំភ្លឺឱ្យបានច្បាស់នូវវិសាលភាពពាក់ព័ន្ធទៅនឹងការបោសសម្អាតផ្ទៃក្នុង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅសហមេធាវីការពារក្ដីលោក នួន ជា ដើម្បីធ្វើការឆ្លើយតប ឬក៏ធ្វើការកត់សម្គាល់ចំពោះសំណើសុំរបស់ក្រុមមេធាវីការពារក្ដីលោក

ខៀវ សំផន នេះ ប្រសិនបើមាន។

**លោក វិចទ័រ កូប៉េ៖**

បាទ លោកប្រធាន ខ្ញុំគិតថា យើងយល់ស្របស្ទើរតែទាំងស្រុងជាមួយអ្វីដែលមេធាវីការពារក្ដី ខៀវ សំផន បានបញ្ជាក់ជូនអង្គជំនុំជម្រះ គឺនេះ គឺជាការពិត ដែលគាត់និយាយថា "ការបោសសម្អាតផ្ទៃក្នុង" ដែលយើងបញ្ជាក់នៅក្នុងសេចក្ដីសន្និដ្ឋានរបស់យើងហើយ គឺមិនមែនជាបទឧក្រិដ្ឋ<>ទេ ដោយ-សារថា អំពើនោះ គឺគេបោសសម្អាតមនុស្សនៅក្នុងជួរបក្សមិនមែនជាបទឧក្រិដ្ឋប្រឆាំងមុនស្សជាតិ ឬក៏បទឧក្រិដ្ឋផ្សេងទៀតទេ។ វាជាអំពើការកំណត់ប្រភេទនៃហេតុការណ៍តែប៉ុណ្ណោះទេ។ ដូច្នេះ យើងទទួលស្គាល់ថា ពាក្យនេះគឺជាពាក្យមួយដែលយើងដាក់នៅក្នុងអត្ថន្តរ។ ប៉ុន្តែយើងត្រូវតែឲ្យច្បាស់ថា ទាក់ទងការបោសសម្អាតដែលថា ក្នុងពាក្យ "ការបោសសម្អាតផ្ទៃក្នុង" នេះមិនមែនជាបទឧក្រិដ្ឋទេ។ ដោយបានបញ្ជាក់លើបញ្ហាបែបនេះ គឺថាទាក់ទងនឹងបញ្ហានេះដែរ ខ្ញុំមិនយល់អំពីទឡ្ហីករណ៍របស់ដើមបណ្ដឹង -- មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងការឆ្លើយតបទៅនៅក្នុងសេចក្ដីសន្និដ្ឋានរបស់យើងទាក់ទងទៅនឹងការបះបោរ។ បញ្ហាទាក់ទងនឹងការបះបោរនោះ អ្វីដែលខ្ញុំចាប់ច្បាស់នោះ គឺថាយើងនិយាយថា ការបោសសម្អាតនៅភូមិភាគពាយ័ព្យ មិន<>ស្ថិតនៅក្នុងផ្នែកនៃដីកាដំណោះស្រាយ<ទេ> ហើយសាក្សីដែលមកពីភូមិភាគពាយ័ព្យ និយាយអំពីហេតុការណ៍នានា ដែលនៅក្នុងភូមិភាគនោះ គឺថាមិនមានភាពពាក់ព័ន្ធ។ នេះជាការអះអាងរបស់ពួកគាត់។

[១០:២៩:០៩]

ប៉ុន្តែភូមិភាគពាយ័ព្យ ជាកម្មាភិបាលភូមិភាគនោះ ក៏ត្រូវបានគេបញ្ជូនមកស-២១ គេឃុំខ្លួននៅស-២១ ហើយភស្តុតាងទាំងអស់<>មកពីភូមិភាគពាយ័ព្យក៏<ទៅជា>មានភាពពាក់ព័ន្ធ <ប្រហែលជាមិន>ទាក់ទងទៅនឹងបញ្ហាករណីរបស់មេធាវី ខៀវ សំផន <ទេ ប៉ុន្តែវាទាក់ទងខ្លាំងទៅនឹង>ករណីរបស់យើងខ្ញុំ<>។ ប៉ុន្តែយើងពិនិត្យឃើញថា កម្មវត្ថុនៃការបោសសម្អាតផ្ទៃក្នុងនេះ គឺវាមានសារសំខាន់ណាស់ ជាក់ស្ដែងណាស់ចំពោះទ្រឹស្ដីការពាររបស់យើងខ្ញុំ ពីព្រោះវាជាផ្នែកនៃទឡ្ហីករណ៍របស់យើងខ្ញុំដែលថា ពួកអ្នកដែលគេចាប់ខ្លួនហ្នឹង ដោយសារថា ពួកគេ គេចោទថា មានការរៀបចំបង្កើតផែនការធ្វើរដ្ឋប្រហារ <ការបះបោរ ការវាយប្រហារប្រដាប់អាវុធមកលើមជ្ឈិម>...។ល។ គឺមូលហេតុដែលគេចាប់នៅពេលនោះ យើងយល់ថា វាផ្អែកលើអំពើរបស់គេ។ អ៊ីចឹងគឺយើងត្រូវតែយល់ឲ្យច្បាស់អំពី ថាតើមូលហេតុនៃការចាប់ខ្លួនមនុស្សភាគច្រើននៅភូមិភាគពាយ័ព្យដែលយកមកស-២១ នោះ ក៏ដូចម្ដេច។

អ៊ីចឹងគឺថា យើង ទោះបីជាយើងខ្ញុំមិនជំទាស់ពីការបង្ហាញខ្លួនសាក្សីហ្នឹងដែរ។ ក៏ប៉ុន្តែយើងខ្ញុំនៅតែយល់ទាំងស្រុងថាមេធាវី ខៀវ សំផន លើកឡើងហ្នឹង គឺជាមូលហេតុត្រឹមត្រូវ ពីព្រោះគិតថា ការបោសសម្អាតផ្ទៃក្នុងខ្លួនឯងនេះ គឺវាមិនមែនជា<ប្រធានបទពាក់ព័ន្ធនោះទេ នៅពេលដែលយើងកំណត់និយមន័យបទឧក្រិដ្ឋជាក់លាក់នោះ>។

**ប្រធានអង្គជំនុំ៖**

អរគុណ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហព្រះរាជអាជ្ញា ដើម្បីធ្វើសារណាតបទៅនឹងសំណើសុំរបស់ក្រុមសហមេធាវីការពារក្តីលោក ខៀវ សំផន។

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម។

<សូម>និយាយដោយសង្ខេប <ប្រហែល ជាវាអាចជួយ>យើង<បាន ដោយ>ចូលទៅ<មើលសេចក្តីសង្ខេបរបស់>សាក្សីរូបនេះ<ដោយផ្ទាល់ ដើម្បីយល់ពីការជំទាស់របស់>មេធាវី ខៀវ សំផន<>។ <>ផ្អែកទៅលើសេចក្តីសង្ខេបដែលសហព្រះរាជអាជ្ញាដាក់ជូនតុលាការ សាក្សីបានរៀបរាប់អំពីមន្ទីររបស់គាត់នៅខេត្តក្រចេះ បានទទួលលិខិតមកពីមន្ទីរ៨៧០ នៅចុងឆ្នាំ១៩៧៨ គឺណែនាំឲ្យមេដឹកនាំ១១<នាក់ នៅតំបន់ក្រចេះ និង>កងពល<១១៧> ឲ្យជិះយន្តហោះមកភ្នំពេញ។ ហើយគឺនៅក្នុងឯកសារនោះបញ្ជាក់ថា បុគ្គលទាំងអស់នេះ គឺបញ្ជាក់ដោយឯកសារស-២១ គឺអ្នកទាំងអស់នេះ ក៏បានមកជាប់នៅស-២១ នៅខែធ្នូ ឆ្នាំ១៩៧៨។ <ដូច្នេះ ដូចដែលក្រុមមេធាវី>លោក នួន ជា <ទើបតែលើកឡើងអ៊ីចឹង នៅពេលដែលភស្តុតាងពាក់ព័ន្ធទៅនឹងរបៀបដែលគេបញ្ជូនមនុស្សទៅ>ស-២១ <គឺវាទាក់ទងទៅនឹងសវនាការនេះ។> ការបោសសម្អាត<> មិនមែនបទឧក្រិដ្ឋដោយខ្លួនឯង<ទេ> ប៉ុន្តែវាពាក់ព័ន្ធទៅនឹងគោលនយោបាយ ហើយនិងការអនុវត្តដែលនាំឲ្យមានការ<ធ្វើ>ទារុណកម្ម ការ<ធ្វើឃាត> ហើយការនឹងសម្លាប់ផ្តាច់ផ្តិល <រួមទាំងអ្នកដែលជាប់នៅ>មន្ទីរស-២១ <និង>មន្ទីរ<សន្តិ-សុខ>ផ្សេងៗទៀត។ ដូច្នេះយើងឃើញ<មានភាពជាប់ពាក់ព័ន្ធ>ជាក់ស្តែងហើយ។ <ជាការពិត> លោក ខៀវ សំផន គឺជាសមាជិកនៅក្នុងមន្ទីរ៨៧០ <នៅពេល>ដែល<>មានលិខិតចេញពីមន្ទីរនេះទៅ <ដូច្នេះយើងយល់ពីមូលហេតុដែលក្រុមលោក ខៀវ សំផន មិនចង់ស្តាប់សក្ខីកម្មសាក្សីនេះ ប៉ុន្តែវា>ច្បាស់ណាស់<ថាជាប់>ពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវ<របស់>គាត់ ហើយ<ជាប់ពាក់ព័ន្ធទៅនឹង>ភស្តុតាង<អំពី>គោលនយោបាយ<កំណត់មុខសញ្ញា>ខ្មាំង <ហើយនិងតួនាទីរបស់ ស-២១ នៅ

ក្នុងគោលនយោបាយ>នោះ។

[១០:៣៣:១៣]

**ប្រធានអង្គជំនុំ៖**

ផ្តល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងភាគីទាំងអស់។ ខ្ញុំនឹងពន្យល់ដោយផ្ទាល់មាត់នូវអ្វីដែលយើងបានពន្យល់ជាលាយលក្ខណ៍អក្សររួចមកហើយ នៅក្នុងចម្លើយតបពីរដែលយើងបានឆ្លើយទៅនឹងសំណើសុំកោះហៅសាក្សីបន្ថែមរបស់មេធាវីការពារក្តី នួន ជា។ ខ្ញុំសូមយោងឯកសារ E371/1 កថាខណ្ឌ -- សុំទោស E391/1 កថាខណ្ឌ១៤ ដែលយើងបានដាក់កាលពី<ថ្ងៃទី០៤> ខែមេសា ឆ្នាំ២០១៦ និងឯកសារ <E392/1> កថាខណ្ឌ១៥ ដែលយើងបានដាក់នៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៦។ <វាមានសារៈសំខាន់សម្រាប់>ខ្ញុំ<ក្នុងការ>បញ្ជាក់<ដោយ>ផ្ទាល់មាត់<ឲ្យបានច្បាស់លាស់> ពីព្រោះ<ខ្ញុំជឿ>ថាមេធាវីការពារក្តី <នួន ជា> មិនយល់អំពី<អ្វីដែលយើងបានបញ្ចូលក្នុងចម្លើយតបទាំងអស់នេះ>។ អ្វីដែលយើងបានបញ្ជាក់នោះគឺថាដូចតទៅ អង្គជំនុំជម្រះទទួលបាន បណ្តឹងពាក់ព័ន្ធនឹង<អង្គ>ហេតុពីរប្រភេទ គឺជាអង្គហេតុដែលអាចឲ្យកំណត់អំពីអត្ថិភាពនៃគោលនយោបាយនៅក្នុងក្របខ័ណ្ឌនៃសហឧក្រិដ្ឋកម្មរួម។ ហើយ<នៅក្នុង>វគ្គរបស់យើងនេះគឺ <គោលនយោបាយ>អប់រំកែប្រែសមាសភាពមិនល្អ និងការកម្ទេចខ្មាំង គឺអង្គជំនុំជម្រះទទួលបណ្តឹងអំពីអង្គហេតុដែលអាចឲ្យខ្លួនកំណត់ឲ្យបានអំពីអត្ថិភាពនៃគោលនយោបាយ ហើយអង្គជំនុំជម្រះ <> ក៏ទទួលបណ្តឹងអំពីអង្គហេតុដែលអាចឲ្យអង្គជំនុំជម្រះកំណត់អំពីអត្ថិភាពនៃឧក្រិដ្ឋកម្ម ដែលបានចោទប្រកាន់ចំពោះ លោក នួន ជា និង ខៀវ សំផន។ ចំពោះឧក្រិដ្ឋកម្មយើងយល់ច្បាស់ហើយ ថាឧក្រិដ្ឋកម្មទាំងអស់នេះត្រូវបានកម្រិតត្រឹមតែមន្ទីរសន្តិសុខបី ដែលបានលើកឡើងដោយសហមេធាវីការពារក្តីលោក ខៀវ សំផន រួចមកហើយ គឺភ្នំក្រោល អូរកន្សែង និងមន្ទីរស-២១។ ដូច្នេះនេះយើងនិយាយអំពីឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់ចំពោះជនជាប់ចោទនៅក្នុងសំណុំរឿងយើងនេះ។ ពាក់ព័ន្ធទៅនឹងការកំណត់អំពីអត្ថិភាពនៃគោលនយោបាយ តាមទស្សនៈរបស់យើងអង្គជំនុំជម្រះទទួលបានបណ្តឹងពាក់ព័ន្ធទៅនឹងអង្គហេតុដែលជាប់ពាក់ព័ន្ធទៅនឹងការបោសម្អាតនៅភូមិភាគឧត្តរ និងបូព៌ាតែប៉ុណ្ណោះ។ ទោះជាយ៉ាងណាក៏ដោយ ជាការពិតណាស់ សាក្សីមួយចំនួនអាចផ្តល់សក្ខីកម្មពាក់ព័ន្ធទៅនឹង

ផ្នែកផ្សេងទៀតនៃសវនាការយើងនេះ។ ជាពិសេស គឺផ្នែកពាក់ព័ន្ធទៅនឹងតួនាទីរបស់ជនជាប់ចោទ និងសហឧក្រិដ្ឋកម្មរួម។

[១០:៣៦:២២]

ដើម្បីសង្ខេបមកវិញ នៅពេលដែលយើងនិយាយអំពីគោលនយោបាយអប់រំ កែប្រែសមាសភាពមិនល្អ និងការកម្ទេចខ្មាំង អង្គជំនុំជម្រះធ្វើការជំនុំជម្រះអង្គហេតុពាក់ព័ន្ធទៅនឹង<ការបោសសម្អាតនៅ>ភូមិភាគបូព៌ា និងភូមិភាគឧត្តរ។ ក៏ប៉ុន្តែនិយាយ បើយើងនិយាយអំពីឧក្រិដ្ឋកម្មដែលចេញមកពីការអនុវត្តគោលនយោបាយទាំងអស់នេះ អង្គជំនុំជម្រះអាចជំនុំជម្រះទៅលើឧក្រិដ្ឋកម្មដែលកើតតែអូរកន្សែង ភ្នំក្រោល និងមន្ទីរ ស-២១ តែប៉ុណ្ណោះ។ នេះជាការយល់អំពីវិសាលភាពនៃបណ្ដឹងរបស់សហចៅក្រមស៊ើបអង្កេតមកកាន់អង្គជំនុំជម្រះ។ ដូច្នេះ អ្វីដែលអង្គជំនុំជម្រះបានកំណត់ក្នុងការស្ដាប់ចម្លើយសាក្សីនាពេលខាងមុខនេះ ខ្ញុំគិតថាវាមានភាពពាក់ព័ន្ធផងដែរ។ ហើយក៏វាជាប់ពាក់ព័ន្ធទៅនឹងតួនាទីរបស់ជនជាប់ចោទ និងសហឧក្រិដ្ឋកម្មរួម ដែលយើងនឹងធ្វើការជំនុំជម្រះនៅពេលចុងក្រោយផងដែរ។

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមឆ្លើយតបដោយខ្លី។ <ជាបឋមគឺ>ចម្លើយ<តប>ខ្លី<មួយទៅនឹង>សហព្រះរាជអាជ្ញាអន្តរជាតិ។ ខ្ញុំគិតថាយើងដូចជាមិនយល់គ្នាទាល់តែសោះ គាត់ដូចជាមិនយល់អំពីសំណើរបស់យើង។ យើងស្នើឲ្យតែអង្គជំនុំជម្រះបំភ្លឺតែប៉ុណ្ណោះ។ <ជាការពិតហើយ>យើង<និយាយអំពី>សាក្សី 2-TCW-1005 <>។ <ប៉ុន្តែនៅពេលនេះ អង្គជំនុំជម្រះបានចេញសេចក្ដីសម្រេចមួយ ដែល>យើងមិន<អាច>ជំទាស់<បាន។ ដូច្នេះសំណើរបស់យើងគឺ>អត់ជំទាស់<នឹងការបង្ហាញខ្លួនរបស់សាក្សីនេះទេ។ មិនជំទាស់សោះតែម្ដង>។ វាគ្រាន់តែជាការស្នើសុំឲ្យអង្គជំនុំជម្រះបំភ្លឺអំពីវិសាលភាព។ ហើយខ្ញុំក៏គាំទ្រទៅនឹងការលើកឡើងរបស់សហមេធាវីនាំមុខ គឺវាមានបញ្ហា ថាតើយើងនឹងសួរសាក្សីរូបនោះយ៉ាងម៉េច? ហើយយើងធ្វើយ៉ាងម៉េច? ពិតណាស់ដូចដែលសហមេធាវីនាំមុខលើកឡើង។ យើងធ្វើការវិភាគដូចគ្នា ពាក់ព័ន្ធទៅនឹងអង្គហេតុ ដែលសហចៅក្រមស៊ើបអង្កេតប្ដឹងមកកាន់អង្គជំនុំជម្រះពាក់ព័ន្ធទៅនឹងភូមិភាគបូព៌ា និងភូមិភាគឧត្តរ។

[១០:៣៨:២៥]

ឥឡូវនេះ យើងត្រឡប់មកនិយាយអំពី<សំណួរ>ដដែលៗ<ឡើងវិញ គឺថា បើសិនវាមិនមែនជាផ្នែកនៃ>វិសាលភាព<នៃការជំនុំជម្រះទេ> ម៉េចក៏វាមានជាប់ពាក់ព័ន្ធ ហើយអង្គជំនុំជម្រះនឹងប្រើភស្ដុ-

តាង<>នេះ<ដើម្បីអ្វី>។ អ៊ីចឹងហើយបានជាយើងចោទសួរម្តងហើយ ម្តងទៀត ដោយសារតែយើងមិនទាន់បានទទួលនូវសំអាងហេតុរបស់អង្គជំនុំជម្រះពាក់ព័ន្ធទៅនឹងសាក្សីផ្សេងទៀត ដែលអង្គជំនុំជម្រះត្រៀមនឹងកោះហៅមកសួរនៅក្នុងវគ្គបោះសម្អាតផ្ទៃក្នុងនេះ។ វាមានបញ្ហាចោទឡើង បើយើងពិនិត្យមើលទៅលើអង្គហេតុ ទៅលើការសង្ខេបសំអាងហេតុហ្នឹងគឺ វាពាក់ព័ន្ធទៅនឹងវិសាលភាពរបស់អង្គជំនុំជម្រះ។ បើយើងនិយាយអំពីតួនាទីរបស់ជនជាប់ចោទ និងសហឧក្រិដ្ឋកម្មរួម <គឺ>វាមិនបញ្ហាអ្វីទេ។ ក៏ប៉ុន្តែបើយើងនិយាយអំពីពិរុទ្ធភាព និងតួនាទីរបស់ជនជាប់ចោទទៅលើហេតុការណ៍នោះមួយនោះ <ហើយនាំទៅដល់ការលើកយកអង្គហេតុ ដែលមិនមាន>នៅក្នុងដីកាដំណោះស្រាយ ក៏ដូចជានៅក្នុងដីកាសម្រេចបំបែកនីតិវិធី <នោះយើងពិតជានឹងប្រឈមនឹង>បញ្ហានីតិវិធី។ <តើ>យើង<អាច>ជាន់ឈ្លីនៅវិធាន<៩៨(២) នៃវិធានផ្ទៃក្នុងបានទេ។ មានន័យថា យើងមិនអាចគ្រប់គ្រងទៅលើអង្គ-ហេតុដែលបានកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះបានទេ ហើយ>ប្រសិនបើយើង<>ដកចេញពីសេចក្តីសម្រេចបំបែកនីតិវិធីរបស់ខ្លួននោះ <>អ៊ីចឹងចាំបាច់ធ្វើ<>ដីកាហ្នឹងធ្វើអី សម្រេចបំបែកធ្វើស្អីបើបំបែកហើយ ឲ្យរំលោភទៅលើដីការបស់ខ្លួនដដែល។ <មានបញ្ហាពីរ ដែលជាលទ្ធផលចេញមកពីការសង្កេតរបស់សហមេធាវីនាំមុខ ដូច្នេះនៅទីនេះយើងកំពុងតែប្រឈមនឹង>បញ្ហានីតិវិធី ដែលយើងស្នើសុំឲ្យអង្គជំនុំជម្រះបំភ្លឺឲ្យបានច្បាស់ពាក់ព័ន្ធនឹងចំណុចនេះ ពីព្រោះថា <បញ្ហានេះនឹងជំពាក់ជំពិនទៅនឹងលទ្ធភាពរបស់យើងក្នុងការស្នើសុំកោះហៅសាក្សី ហើយប្រាកដណាស់ វាក៏ប៉ះពាល់ទៅដល់វិធីដែល>យើង<ត្រូវ>ជំទាស់<បើសិនជាយើងជឿថា មានសំណួរជាក់លាក់មួយចំនួន>នៅក្រៅវិសាលភាព<នៃការជំនុំជម្រះនេះ>។ អ៊ីចឹងបានជាខ្ញុំស្នើសុំឲ្យមានការបំភ្លឺឲ្យបានច្បាស់ត្រង់ចំណុចនេះ ហើយមិនមែនជាការជំទាស់ទេ សុំបញ្ជាក់ម្តងទៀត។

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៤៣:៣៦]

**ប្រធានអង្គជំនុំ៖**

បាទ ហើយអង្គជំនុំជម្រះអរគុណចំពោះមតិយោបល់របស់ភាគីពាក់ព័ន្ធ ដែលបានធ្វើសារណាតបទៅនឹងសំណើសុំរបស់មេធាវីការពារក្តីលោក ខៀវ សំផន សុំឲ្យបំភ្លឺនូវបញ្ហាពាក់ព័ន្ធដែលបង្ហាញនៅក្នុងឯកសារ E420 របស់ខ្លួន។ ហើយអង្គជំនុំជម្រះនឹងយកបញ្ហានេះទៅពិនិត្យ ពិចារណា ហើយនិងចេញនូវសេចក្តីបំភ្លឺបញ្ជាក់ទៅលើបញ្ហានេះជូនភាគីដែលបាន -- ម្ចាស់សំណើ ហើយនិងភាគីពាក់ព័ន្ធឲ្យ

បានជ្រាប។ ប៉ុន្តែអង្គជំនុំជម្រះសូមកត់សម្គាល់ថា ដោយសារស្ថានភាពបញ្ហានេះ គឺមានចរិតលក្ខណៈស្មុគស្មាញ ហើយផ្តួបផ្សំជាមួយនឹងសំណើសុំដែលទើបដាក់ចុងម៉ោង កាលពីចុងថ្ងៃសុក្រនៅសប្តាហ៍មុន ហើយយើងធ្វើជាបន្ទាន់នៅពេលនេះ ដូច្នេះ គឺអង្គជំនុំជម្រះត្រូវការពេលវេលា ពិនិត្យពិចារណាឲ្យបានសមស្របមុននឹងចេញសេចក្តីណែនាំឆ្លើយតបទៅនឹងបញ្ហានេះ។ ដូច្នេះ អង្គជំនុំជម្រះមិនអាចធ្វើសវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCW-236 -- 2-TCCP-236 នៅក្នុងថ្ងៃនេះបានទេ។

អង្គជំនុំជម្រះសម្រេចថា សវនាការនៅថ្ងៃនេះ គឺសម្រេចផ្អាកកិច្ចដំណើរការ សវនាការត្រឹមនេះសិន ហើយនិងសវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃអង្គារ ទី២៨ ខែមិថុនា ឆ្នាំ២០១៦ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្ម ដើមបណ្តឹងរដ្ឋប្បវេណី ដែលបានគ្រោងទុក។

សវនាការនៅថ្ងៃនេះ ផ្អាកត្រឹមនេះ ហើយលើកទៅធ្វើនៅថ្ងៃស្អែកណ៎ះ អ្នកបកប្រែភាសានិយាយឲ្យច្បាស់លាស់ គឺធ្វើនៅថ្ងៃស្អែក ថ្ងៃអង្គារ ទី២៨ ខែមិថុនា ឆ្នាំ២០១៦ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក ដូចសព្វដងអ៊ីចឹង។ ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-236 តាមកាលវិភាគដែលបានគ្រោងទុក ដែលមិនបានធ្វើសវនាការនៅថ្ងៃនេះហ្នឹង គឺលើកទៅបន្តធ្វើនៅថ្ងៃស្អែក។

ហើយអង្គជំនុំជម្រះបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនជនជាប់ចោទទាំងពីររូប ត្រឡប់ទៅកាន់មន្ទីរឃុំឃាំង អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការនៅថ្ងៃស្អែកវិញឲ្យបានមុនម៉ោងប្រាំបួនព្រឹក។ ដោយឡែកខាងមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ជូនដើមបណ្តឹងរដ្ឋប្បវេណីទៅកន្លែងដែលគាត់ស្នាក់នៅវិញ ហើយនិងឲ្យអញ្ជើញគាត់មកចូលរួមផ្តល់សក្ខីកម្មនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោយឈរ!

*(សវនាការផ្អាកនៅម៉ោង ១០:៤៦ នាទី)*